**BMI0078**

# សម្ភាសន៍ជាមួយឈ្មោះ សែម ហឿន ភេទប្រុស អាយុ៩១ឆ្នាំ

## មុខងារខ្មែរក្រហមៈ ទាហាន

ស្រុកកំណើតនៅភូមិធម្មនាជ ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ

សព្វថ្ងៃរស់នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ ឡុង ដានី

០០:៥៩:៥៣

៣៤ទំព័រ

ហឿន : អាហ្នឹងនិយាយថាឲ្យតាមត្រឹមត្រូវវាមិននេះទេ នេះនិយាយតាមមើលឃើលទេណា៎ ។

ដានី : បាទ!តាមឃើញតាមពូចាំ កន្លែងណាពូចាំជួយជំរាបប្រាប់ខ្ញុំ កន្លែងណាអត់ចាំក៏អត់អីដែរ ។

ហឿន : បាទ!

ដានី : បាទ!ហើយដំបូងខ្ញុំសុំស្គាល់ឈ្មោះពូសុន ពូឈ្មោះអីទៅ?

ហឿន : បាទ!ខ្ញុំឈ្មោះ សែម ហឿន ។

ដានី : សែម ហឿន?

ហឿន : បាទ!សែម ហឿន ។

ដានី : បាទ!ពូអាយុប៉ុន្មានហើយសព្វថ្ងៃ?

ហឿន : បាទ!ខ្ញុំអាយុ៩១ឆ្នាំ ។

ដានី : សព្វថ្ងៃរស់នៅភូមិអីដែរ សព្វថ្ងៃហ្នឹង?

ហឿន : បាទ!ខ្ញុំរស់នៅភូមិផ្គាំ ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យយើងហ្នឹង ។

ដានី : ស្រុកកំណើតពូនៅណាដែរ?

ហឿន : បាទ!ស្រុកកំណើតខ្ញុំនៅឯខេត្តកំពង់ធំនោះ ខ្ញុំនៅអ៊ើភូមិធម្មនាជ ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។

ដានី : ប្រពន្ធពូគាត់អ្នកស្រុកណាដែរ?

ហឿន : បាទ!អ្នកស្រុកហ្នឹង អ្នកស្រុកផ្គាំហ្នឹង ។

ដានី : គាត់ឈ្មោះអីដែរ?

ហឿន ៖ ឈ្មោះ តាមអត្តសញ្ញាណប័ត្រ ឈ្មោះ ទុន សិភ ។

ដានី ៖ អាយុប៉ុន្មានហើយមីង?

ប្រពន្ធ ៖ ខ្ញុំអាយុ៤៩ឆ្នាំហើយ ។

ដានី ៖ ពូមានកូនចៅប៉ុន្មាននាក់ហើយសព្វថ្ងៃ?

ហឿន ៖ បាទ!៥នាក់ ។

ដានី ៖ កូន៥នាក់ ស្រីប៉ុន្មាន ប្រុសប៉ុន្មាន?

ហឿន ៖ ប្រុស៤ ស្រី១ ។

ដានី ៖ សព្វថ្ងៃពូប្រកបរបររកស៊ីធ្វើអីដែរ?

ហឿន ៖ ធ្វើស្រែ ។

ដានី ៖ ធ្វើស្រែ?

ហឿន ៖ បាទ!

ដានី ៖ ធ្វើអីទៀតក្រៅពីធ្វើស្រែ?

ហឿន ៖ មានអីខ្ញុំនៅទាហានដែរ នៅកងយុទ្ធពលខេមរៈភូមិន្ទ ។

ដានី ៖ ទាហាន?

ហឿន ៖ បាទ!

ដានី ៖ កងពលនៅណាទៅ កងពលអន្តរភាព?

ហឿន ៖ បាទ!កាលមុនខ្ញុំនៅកងពល៥១ ដល់ក្រោយម៉ោខ្ញុំមានបញ្ហាបន្តិចទៅ គេបញ្ជូនខ្ញុំឲ្យទៅនៅកន្លែងភូមិភាគ៥ យើងតែម្តង នៅកន្លែងភូមិភាគ៥ ។

ដានី ៖ ពូខស្បាហ៍ទៅលេងស្រុកកំណើតទេ?

ហឿន ៖ បាទ!យូរៗទៅ១ដងដែរ ជួនកាល១ឆ្នាំ២ឆ្នាំអីទៅលេង១ដងអីហ្នឹង មិនសូវបានទៅញឹកញាប់ទេ ។

ដានី ៖ ឪពុកម្តាយពូគាត់នៅរស់ទេ ឬក៏?

ហឿន ៖ នៅតែឪពុក ម្តាយគាត់ស្លាប់ហើយ ។

ដានី ៖ ពួកគាត់ឈ្មោះអីទៅ?

ហឿន ៖ ឪពុកឈ្មោះ សែម ដុន ។

ដានី ៖ គាត់នៅស្រុកកំណើតរបស់ពូឬក៏នៅណា?

ហឿន ៖ បាទ!គាត់នៅហ្នឹង នៅភូមិហ្នឹងឯងនៅភូមិធម្មនាជ ឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ ។

ដានី ៖ ចុះម្ដាយពូ?

ហឿន ៖ ម្ដាយស្លាប់តាំងពីខ្ញុំនៅតូចម៉េះ ។

ដានី ៖ ស្លាប់តាំងពីនៅតូច?

ហឿន ៖ បាទ!

ដានី ៖ គាត់ឈ្មោះអីទៅ?

ហឿន ៖ គាត់ឈ្មោះ ពៅ ភាព ។

ដានី ៖ បាទ!ពូមានបងប្អូនបង្កើតប៉ុន្មានទៅ?

ហឿន ៖ មានបងប្អូនបង្កើត៣នាក់ ។

ដានី ៖ ៣នាក់ហ្នឹងប្រុសប៉ុន្មាន ស្រីប៉ុន្មាន?

ហឿន ៖ ប្រុសទាំង៣ហ្នឹង

ដានី ៖ កូនទីប៉ុន្មានពូ?

ហឿន ៖ ខ្ញុំទី១ ។

ដានី ៖ បងគេបង្អស់អេស៎?

ហឿន ៖ បាទ!

ដានី ៖ បាទ!ហើយចុះ៣នាក់ហ្នឹងស្រីប៉ុន្មានប្រុសប៉ុន្មាន?

ហឿន ៖ ប្រុសទាំង៣ហ្នឹង ៣នាក់ប្រុសទាំង៣ ។

ដានី ៖ ហើយកាលហ្នឹងពូបានរៀនសូត្រដល់ថ្នាក់ណាដែរ កាលពីក្មេងៗ ។

ហឿន ៖ ខ្ញុំនៅក្មេងកាលនោះ ស្រុកយើងមានសង្គ្រាមផង ដោយខ្មែរក្រហមគេតស៊ូប្រឆាំងជា មួយលន់ ណុល បាទ!អញ្ចឹងទៅយើងរៀនបានតិចតួច ខ្ញុំរៀនបានថ្នាក់១១-១២ពីដើមហ្នឹងណា៎ ពីដើមយើងរៀនពីលើមកក្រោម?

ដានី ៖ បាទ!

ហឿន ៖ ឥឡូវគេរៀនពីក្រោមទៅលើវិញ ។

ដានី ៖ បាទ!ចេះអានចេះសរសេរដែរកាលហ្នឹង?

ហឿន ៖ បាទ!ចេះអាន ចេះសរសេរ ចេះអីបាន ។

ដានី ៖ ឈប់រៀនពេលណា កាលហ្នឹង?

ហឿន ៖ បាទ!ខ្ញុំឈប់រៀនតាំងពីយើងរដ្ឋប្រហារចប់ទៅ ខ្មែរក្រហមគេចប់ទៅ ។

ដានី ៖ បាទ!

ហឿន ៖ កាលហ្នឹងគេជ្រើសរើសថាកូនកម្មាភិបាលហ្នឹងឲ្យទៅរៀនស្រុកចិន ដល់ទៅៗវាអត់បានទៅរៀននៅស្រុកចិន គេបង្រៀនខាងយោធាទៅវិញ គេឲ្យខ្ញុំធ្វើកងយោធា ធ្វើកង មជ្ឈិមដើម្បីទៅវៃយួនយកកម្ពុជាក្រោមវិញ ។

ដានី ៖ អ្ហូ!ឆ្នាំណាហ្នឹង?

ហឿន ៖ បាទ!តាំងពីឆ្នាំ៧៦-៧៧មោ៉ ។

ដានី ៖ អញ្ចឹងពេលពូរៀនចប់ថ្នាក់ទី១១ហ្នឹង ពេលឈប់រៀនហ្នឹងឆ្នាំណា?

ហឿន ៖ ឆ្នាំរៀនតាំងពីរដ្ឋប្រហារឆ្នាំ៧០ ។

ដានី ៖ អ្ហូ!រដ្ឋប្រហារឆ្នាំ៧០?

ហឿន ៖ បាទ!

ដានី ៖ ពេលឈប់រៀនហើយធ្វើអីទៅ?

ហឿន ៖ ធ្វើស្រែធម្មតា ។

ដានី ៖ ឈប់រៀនហើយ ធ្វើស្រែជាមួយឪពុកម្ដាយ?

ហឿន ៖ ហ្នឹងហើយ ។

ដានី ៖ ធ្វើស្រែដល់ពេលណាទៅ បានចេញពីផ្ទះ?

ហឿន ៖ ឆ្នាំ៧៦ ។

ដានី ៖ ទល់តែឆ្នាំ៧៦?

ហឿន ៖ បាទ!គេចប់ហើយ គេច្បាំងចប់ហើយ ។

ដានី ៖ អ្ហូ!ទល់តែបែកភ្នំពេញឆ្នាំ៧៥ហើយ?

ហឿន ៖ បាទ!បែក៧៥ហើយ ៧៦យើងគេចាប់ចូលរៀបទ័ពអីៗ ។

ដានី ៖ អញ្ចឹងពេលបែកភ្នំពេញឆ្នាំ៧៥ហ្នឹងពូធ្វើអីទៅ?

ហឿន ៖ បែកហ្នឹងក៏ធ្វើស្រែដែរ នៅផ្ទះ ។

ដានី ៖ បែកហើយនៅធ្វើស្រែដែរនៅផ្ទះ?

ហឿន ៖ បាទ!

ដានី ៖ ចុះឪពុកម្ដាយគាត់ធ្វើស្រែដែរ ឪពុកម្ដាយពូ?

ហឿន ៖ ធ្វើស្រែដែរ ប៉ុនគាត់ធ្វើមេឃុំម្ដងកាលសម័យនោះណា៎ ។

ដានី ៖ នៅសម័យនោះគាត់ធ្វើមេឃុំ?

ហឿន ៖ បាទ!

ដានី ៖ អញ្ចឹងគាត់ធ្វើមេឃុំតាំងពីរដ្ឋប្រហារម៉ោ គាត់ធ្វើមេឃុំរហូត?

ហឿន ៖ បាទ!

ដានី ៖ កាលហ្នឹងដីរបស់ពូហ្នឹង ខាងស្រុកពូហ្នឹងស្ថិតនៅក្នុងសម័យកងទ័ពខ្មែរក្រហម?

ហឿន ៖ បាទ!ខាងកម្ពុជាប្រជាធិបតេយ្យគេកាន់កាប់ប្រទេសជិតនាំហ្នឹង ។

ដានី ៖ អ្ហូ!ធ្វើសង្កាត់ កាលហ្នឹងគេហៅសង្កាត់?

ហឿន ៖ បាទ!

ដានី ៖ សង្កាត់តាំងក្រសាំងហ្នឹង?

ហឿន ៖ បាទ!

ដានី ៖ អញ្ចឹងពេលបែក៧៥ហើយពូនៅធ្វើស្រែនៅឡើយទេ?

ហឿន ៖ បាទ!ធ្វើស្រែ ។

ដានី ៖ ធ្វើស្រែដល់ឆ្នាំណា បានគេជ្រើសរើសពូ?

ហឿន ៖ ឆ្នាំ៧៦ បានគេថាជ្រើសរើសកូនកម្មាភិបាលឲ្យទៅរៀននៅស្រុកចិនហ្នឹង ឪពុកគាត់នឹកឃើញចង់ឲ្យទៅនឹងគេដែរ ក្រែងលោបានទៅនោះខែងវែងអីនឹងគេ ដល់វាអត់បានទៅ ទៅចូលទៅហាត់ជាយោធា ទៅវៃយួនឯណាយកកម្ពុជាក្រោមវិញ ទៅបញ្ចូសកងពន្ធិតទឹក ព្រោះដីយើងបាត់ដែរ មិនអញ្ចឹង បាត់មកទល់ឥឡូវ ។

ដានី ៖ ទៅរៀនយោធាវិញ?

ហឿន ៖ បាទ!ទៅរៀនយោធា ខ្ញុំរៀនបានប្រហែល៦ខែ គេបញ្ជូនឲ្យទៅវៃយួនបណ្តោយ ។

ដានី ៖ កាលហ្នឹងគេប្រាប់ថាម៉េច យើងទៅរៀនយោធាវៃជាមួយកម្ពុជាក្រោមហ្នឹងគេប្រាប់ថាម៉េចទៅ?

ហឿន ៖ មុនដំបូងគេប្រាប់ថាជ្រើសរើសកូនកម្មាភិបាលឲ្យទៅរៀននៅស្រុកចិន ។

ដានី ៖ បាទ!

ហឿន ៖ បាទ!អញ្ចឹងយើងនៅក្មេងៗដែលហ្នឹងតូចៗ ដល់ពេលត្រូវទៅនឹងវា មិនដឹងជាឡើងឡានប្រឡំមិនដឹងជាយ៉ាងម៉េចបែរជាត្រូវទៅយោធាទៅវិញ ទៅហាត់ជាយុទ្ធសាស្រ្តរបស់យោធា កលយុទ្ធ យុទ្ធសាស្រ្ត យុទ្ធវិធីវៃយកកម្ពុជាក្រោមវិញ អាហ្នឹងជាយុទ្ធសាស្រ្តយោធា ជាកងទ័ពរបស់យោធាហើយមិនអញ្ចឹង?

ដានី ៖ បាទ!

ហឿន ៖ បាទ!ទៅហាត់រៀនលូនក្រាប ហ៊ីកហ៊ឺនរបៀបយើងហ៊ឺកហ៊ឺនជាសាលាអញ្ចឹង អ៊ូ!តឹង តែងណាស់ហាត់ បាញ់យូសេតពីលើ យូសេតដែលៀនដាក់បាញ់ពីលើ ហើយយើង លូនពីក្រោម អ្នកណាហានងើបត្រូវ អញ្ចឹងលូនទៅត្រូវកាត់បន្ទាអីក៏ដោយ កាត់ អាចម៍ចំណាស់ក៏ដោយ ទៅហើយ ។

ដានី ៖ គេប្រាប់ថាឲ្យបញ្ជូនទៅរៀននៅស្រុកចិនកូនកម្មាភិបាល ប៉ុន្តែទៅដល់កន្លែងទៅកន្លែង ហាត់កងទ័ពវិញ?

ហឿន ៖ បាទ!ទៅហាត់ទៅកងទ័ព ។

ដានី ៖ កងទ័ពហ្នឹងហាត់នៅកន្លែងណាទៅ?

ហឿន ៖ ហាត់នៅស្រុកព្រៃដើមច័ន្ទខេត្តកំពង់ចាម ។

ដានី ៖ កន្លែងអីគេហៅ?

ហឿន ៖ កន្លែងគេហៅស្រឹបៗហ្នឹង គេហៅអាហ្នឹងមិន ខ្ញុំមិនចាំច្បាស់ទេ នៅត្រង់ហ្នឹងមិនដឹងគេ ហៅស្អីទេ ប៉ុន្តខ្ញុំដឹងថាកន្លែងហ្នឹងគេហៅស្រឹបៗនឹងណា៎ នៅស្រឹបព្រៃដើមច័ន្ទហ្នឹង ។

ដានី ៖ បាទ!ខ្ញុំស្គាល់ខ្ញុំអ្នកកំពង់ចាម ។

ហឿន ៖ អញ្ចឹង?

ដានី ៖ បាទ!

ហឿន ៖ អ៊ូ!ហាត់នៅហ្នឹង៦ខែ បានត្រូវបញ្ជូនទៅយប់ទៅផ្លូវជាតិលេខ៧ទៅ ទៅស្នួំ ទៅ ទួល៥០ ទៅស្នួំ ទៅម្លប់ព្រែកទៅអីនោះណា៎ ។

ដានី ៖ បាទៗ!

ហឿន ៖ បាទ!ទៅវ៉ៃទួល៥០ ទួល៥០ហ្នឹងយួននៅ ទួល៥០ហ្នឹងខ្ពស់ណាស់ ដែលទៅដល់ទេ?

ដានី ៖ ទួល៥០ខ្ញុំអត់ដឹងដែរ ។

ហឿន ៖ បាទ!អាហ្នឹងនៅមុខស្នួំ ។

ដានី ៖ មុខស្នួំហ្នឹង?

ហឿន ៖ បាទ!

ដានី ៖ ដល់ហ្នឹងគេបញ្ជូនឲ្យទៅហ្នឹងបណ្ដោយ?

ហឿន ៖ បាទ!ឲ្យទៅហ្នឹង ។

ដានី ៖ ឆ្នាំ៧៦ហ្នឹងដែរឬក៏ឆ្នាំ?

ហឿន ៖ អាហ្នឹងជិតឆ្នាំ៧៧ហើយ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!យើងរៀបចំដើមឆ្នាំ៧៦ ។

ដានី ៖ បាទ!អញ្ចឹងបញ្ជូនទៅហ្នឹង ទៅនៅហ្នឹងទៅនៅកងពលអីទៅ?

ហឿន ៖ ខ្ញុំទៅនៅកងពលដូចគេដាក់១០៥អញ្ចឹងកាលហ្នឹង កាលហ្នឹងដូចវាយូរទៅ ច្រឡំ១០៥ ឬក៏១០៨ កងពល១០៨ឬ១០៥ នៅម្តុំហ្នឹង បើនៅ បើកងពល ហ៊ុន សែន កងពលខាងហ្នឹងដូចគេដាក់០០៩ ។

ដានី ៖ បើកងពលរបស់ពូ ១០៨ ឬក៏ ១០៥?

ហឿន ៖ បាទ!១០៨នឹង១០៥ហ្នឹងឯង វាជាប់ៗគ្នា២កងពលហ្នឹង ដឹកនាំដោយ តាឆាយ ហ្នឹង ។

ដានី ៖ តាឆាយ?

ហឿន ៖ បាទ!បើ ហ៊ុន សែន កងពលភូមិភាគទេ គាត់ភូមិភាគបូព៌ា ស្វាយរៀង ភូមិភាគ បូព៌ា ។

ដានី ៖ តាឆាយ ហ្នឹងគាត់កាន់ទាំង២ ទាំង១០៥ ១០៨ហ្នឹង?

ហឿន ៖ បាទ!

ដានី ៖ ពីណាគេ ក្រៅពីតាឆាយ នៅគណៈកងពល?

ហឿន ៖ អ្ហូ!មានមេៗច្រើនទៀត ខ្ញុំវាភ្លេចដែរ មានឈ្មោះហឿន ដូចខ្ញុំដែរ អ៊ើ!បងនន បងអីច្រើនដែរ ។

ដានី ៖ កាលហ្នឹងនៅក្នុងកងពលហ្នឹង កងពលរបស់មជ្ឈឹមឬកងពលរបស់ភូមិភាគកណ្តាល?

ហឿន ៖ ពឹដើមមិញវានៅក្នុងភូមិភាគកណ្តាលទេ ទាល់តែក្រោយម៉ោពួថាគាត់ចូលទៅមជ្ឈឹម?

ដានី ៖ បាទ!

ហឿន ៖ ដោយភូមិភាគបូព៌ាហ្នឹង រត់ចូលយួនច្រើន បាទ!ដោយកងពល ហ៊ុន សែនហ្នឹង កងពល ហេង សំរិន នេះរត់ចូលយួនចូលអីយោរយ៉ៃណាស់ ។

ដានី ៖ អ្ហូ!បាទ!តែកងពលរបស់ពូនេះមិនមែនបូព៌ាទេ?

ហឿន ៖ មិនមែនបូព៌ាទេ ខ្ញុំភូមិភាគកណ្តាល ។

ដានី ៖ ទៅនៅព្រំដែនរយៈពេលប៉ុន្មានទៅ?

ហឿន ៖ បាទ!ខ្ញុំនៅប៉ុន្មានឆ្នាំហ្នឹងរហូតដល់យួនវៃដាច់ពីកន្លែងហ្នឹងម៉ោ បានដាច់ខ្ញុំរបួស មុនយួនវៃខ្ញុំរបួស ខ្ញុំវៃនៅទួល៥០ហ្នឹង ខ្ញុំរបួសៗទៅបានគេបញ្ជូនមកដេកពេទ្យរុស្សីយើងពេទ្យ៧មករានោះ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!សម័យ៣ឆ្នាំគេដាក់៧មករា?

ដានី ៖ បាទ!

ហឿន ៖ សព្វថ្ងៃគេដាក់ពេទ្យរូស្សីដដែល?

ដានី ៖ អុឺ!ពេទ្យរូស្សី កាលហ្នឹងពេទ្យ១៧មេសា ។

ហឿន ៖ ហ្នឹងហើយ ពេទ្យ១៧មេសាហ្នឹងខ្ញុំដេកពេទ្យហ្នឹងឯង ។

ដានី ៖ ហើយម៉េចទៀតទៅពេលបញ្ជូនមកដេកពេទ្យ១៧?

ហឿន ៖ បាទ!ដល់អញ្ចឹងខ្ញុំដេកពេទ្យបានរយៈពេល៣ខែ ខ្ញុំជារបួសជាអីអញ្ចឹងទៅ យប់មួយនោះគេថាយួនវ៉ៃហើយ យួនវ៉ៃទីក្រុងភ្នំពេញហ្នឹង បាទ!បានរៀបចំអ៊ីវ៉ែអីវ៉ាន់ហ្នឹងចុះពីហ្នឹងម៉ោគេដឹកឡានអាសែកសង់គេនោះ ដឹកឡានម៉ោឡើងរទេះភ្លើងនៅតាខ្មៅនោះឡើងរទេះភ្លើងម៉ោយើងនេះហ្នឹងឯង ។

ដានី ៖ បាទ!

ហឿន ៖ ម៉ោដល់ចំការចេកយើងបាត់ដំបងនេះ យន្តហោះទម្លាក់ហ្នឹងទៀត ៣-៤គ្រឿងមកទម្លាក់នោះ បានរត់តទៅទៀត ម៉ោបវេលម៉ោអីណេ៎ ម៉ោបវេលឆ្ងាយទៅប៉ៃលិនឆ្ងាយទៅអីទៀតទៅ បាននៅព្រំដែនរហូតទាល់តែយើងត្រូវគ្នា៩១នោះណេ៎ ៩១បានមានសម្ដេចតាជាអ្នកសម្រុះសម្រួលជាតិ អ្នកផ្សះផ្សាជាតិ អ្នកបង្រួបបង្រួមជាតិ ។

ដានី ៖ រត់តៗពីបវេល ប៉ៃលិន រហូតដល់ណាទៅ?

ហឿន ៖ បាទ!ដល់អញ្ចឹងទៅ បានខ្ញុំម៉ោនៅ ខ្ញុំគេចពីហ្នឹងម៉ោ ខ្ញុំម៉ោនៅយើងកងពល៥១៩នេះដែលមេខ្ញុំចាស់មេ ឌុល សារឿន នេះ ។

ដានី ៖ បាទ!

ហឿន ៖ ហើយមេ ប៉ែន រ៉ូយ មេអីហ្នឹង ។

ដានី ៖ បាទៗ!អញ្ចឹងពីប៉ៃលិនម៉ោ ឆ្នាំណាបានមកដល់កងពល៥១៩?

ហឿន ៖ ខ្ញុំម៉ោដល់វាឆ្នាំ វានៅក្នុងឆ្នាំ៧៩ហ្នឹងឯង ៧៩-៨០ហើយដឹង ដាក់ត្រឹម៨០ចុះ ។

ដានី ៖ ចុងឆ្នាំ៧៩-៨០ហ្នឹង?

ហឿន ៖ បាទ!៨០ ។

ដានី ៖ ឆ្នាំ៨០បានមកដល់កន្លែង?

ហឿន ៖ បាទ!៨០បាននៅភ្នំឆត្រែយើងនៅចំការគរ នៅចំការគរភ្នំឆត្រែអីយើងព្រៃមន នេះណេ៎ ។

ដានី ៖ មកកន្លែងហ្នឹងម៉េច ម៉ោដល់កន្លែងចំការគរភ្នំឆត្រហ្នឹងយ៉ាងម៉េចទៅ កាលហ្នឹង?

ហឿន ៖ បាទ!ដល់នេះទៅ បានគេរៀបចំវៃឃ្លូនវៃអី ទ្រង់ទ្រាយធំ ត្រង់ទ្រាយតូចតាម កម្មវិធីនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង ។

ដានី ៖ បាទ!

ហឿន ៖ បាទ!វៃឈ្លបវៃអីអញ្ចឹងទៅ ។

ដានី ៖ កាលហ្នឹងគេរៀបចំជាកងពលប៉ុន្មាននៅភ្នំឆត្រនៅចំការគរហ្នឹង?

ហឿន ៖ បាទ!គេរៀបចំហើយ កងពល បាទ!ជាកងពលដំបូងហ្នឹងគេដាក់កងពលស្អីទេ ក្រោយ ម៉ោបានគេដាក់កងពល៥១៩ហ្នឹង វាកើតក្រោយ ។

ជិតខាង ៖ មុនដំបូងគេដាក់កងពល៥០៨ ។

ហឿន ៖ ទេ!អា៥០៨ហ្នឹងវាបែកចេញពី៥១៩ទេ ។

ដានី ៖ ក្រោយមកឆ្នាំណាបានគេដាក់កងពល៥១៩វិញ?

ហឿន ៖ អ្ហូ!រឿងឆ្នាំហ្នឹងនិយាយអត់ត្រូវដែរ ។

ដានី ៖ បាទ!កងពល៥១៩ហ្នឹង ប្រធានគាត់ឈ្មោះ ឌុល សារឿន?

ហឿន ៖ បាទ!ឌុល សារឿន ។

ដានី ៖ គាត់មានលេខសំងាត់អីទៀត ឌុល សារឿន?

ហឿន ៖ អត់ទេ!ឈ្មោះ គាត់ ឌុល សារឿន ហ្នឹងម៉ង បើលេខគាត់គាត៩១ ។

ដានី ៖ ៩១?

ហឿន ៖ បាទ!លេខសំងាត់ជាលេខ ។

ដានី ៖ ចុះបន្ទាប់ពី ឌុល សារើន ពីណាទៀត?

ហឿន ៖ ឌុល សារឿន ម៉ោមាន ប៉ែន វ៉ុយ មានអីមេកងផងពលសព្វថ្ងៃហ្នឹង ។

ដានី ៖ ប៉ែន វ៉ុយ?

ហឿន ៖ បាទ!

ដានី ៖ ពីណាទៀត?

ហឿន ៖ ប៉ែន វ៉ុយ មានតាម៉ៅ មានវង់ មានឡុងថែម មានអី ព្រំ ស៊ូ មានអី ។

ដានី ៖ ឡុង ថែម ព្រំ ស៊ូ?

ហឿន ៖ បាទ!

ដានី ៖ ហ្នឹងសុទ្ធតែជាគណៈកងពលហើយ?

ហឿន ៖ គណៈកងពល ។

ដានី ៖ អ៊ើ!កងពល៥១៩ហ្នឹងយើងវៃប្រចាំទិសពីត្រឹមណាទៅដល់ត្រឹមណា?

ហឿន ៖ បាទ!នេះស៊ីសុផុនខាងជើងនេះវាជាប់ពីទៅទល់ ដីធំដែរនៅក្នុងស៊ីសុផុនខាងជើងក្នុងខេត្តបន្ទាយមានជ័យហ្នឹង អាហ្នឹងគេដាក់ស៊ីសុផុនខាងជើង ពួកខាងតាប៉ុកតាអីនោះគេដាក់ស៊ីសុផុនខាងត្បូង ។

ដានី ៖ អាហ្នឹងខាងម៉ាឡៃ?

ហឿន ៖ ម៉ាឡៃ តាភាពអីហ្នឹង ។

ដានី ៖ បាទ!នោះខាងសុខភាព?

ហឿន ៖ បាទ!

ដានី ៖ អញ្ចឹងខាងជើងយើងចាប់ពីកូនដីរ៉ៃម៉ោ ។

ហឿន ៖ បាទ!ចាប់ពីយើងអូរបែកជាន់ម៉ោនេះ រហូតទៅទល់ស្រីស្នំស្រីអីនោះ ហើយទៅទន្លេមួយកំណាត់ទៅ ទៅខាង ។

ដានី ៖ បាទ!កាលហ្នឹងអ៊ើមានគេធំជាង ឌុល សារឿនទៀតប្អូនអត់ អ្នកគ្រប់គ្រងធំជាងហ្នឹង?

ហឿន ៖ មាន!ក្រោយម៉ោបានគេដាក់តាហុងមួយទៀត ។

ដានី ៖ សួរ ហុង?

ហឿន ៖ បាទ!សួរ ហុងហ្នឹង ។

ដានី ៖ សួរ ហុង គាត់គ្រប់គ្រងយ៉ាងម៉េចទៅ?

ហឿន ៖ គាត់ជារបៀបថាជាប្រធានទិស ។

ដានី ៖ ប្រធានទិសម៉េច?

ហឿន ៖ អាហ្នឹងដូចថាទិសស៊ីសុផុនខាងជើងអញ្ចឹង ។

ដានី ៖ ឆ្នាំណាបានគេដាក់ចូលតាហុង?

ហឿន ៖ គេដាក់ចូលគាត់ម៉ោហ្នឹងវាឆ្នាំ៨៧-៨៨ហើយ កាលហ្នឹង ទឹមដាក់ម៉ោដែរ ។

ដានី ៖ ធំជាជាងតា សារឿន ទៀត?

ហឿន ៖ បាទ!គាត់ធំ ជាមនុស្សរបស់ថ្នាក់លើ ជាមនុស្សរបស់ប៉ុល ពត ផ្ទាល់ម៉ង់ គាត់ហ្នឹងជាមួយប៉ុល ពត ។ អើស៎!តាមមើលយកទៅដាក់ឯសារស្រាវជ្រាវអីមិនដឹង?

ដានី ៖ បាទ!ខ្ញុំជាអ្នកសរសេរទស្សនាវដ្តីស្វែងរកការពិតអីអញ្ចឹង ដូចថាពេលដែលខ្ញុំសួរនាំពូអីអញ្ចឹងទៅខ្ញុំអាចសរសេរជារឿងរ៉ាវ ដឹងពីពត៌មានអី យើងអាចបោះពុម្ពក្នុងទស្សនាវដ្តីអីអញ្ចឹង ។

ហឿន ៖ បាទ!ដូចការសែត ពត៌មានអីហ្នឹងផ្សាយមានឈ្មោះ នៅជាប់ហ្នឹងម៉ង ។

ដានី ៖ បាទ!អញ្ចឹងពេលដែលតាហុងគាត់ម៉ោអញ្ចឹង យ៉ាងម៉េចទៅ គាត់នៅតែជាប្រធានកងពលដដែល?

ហឿន ៖ បាទ!បងសារឿន គាត់ប្រធានកងពល តាចាន់ តែនេះប្រធានដឹកនាំមានគាត់អញ្ចឹងបើបញ្ជាគ្រប់គ្រងពីក្រោយម៉ោមានថ្នាក់លើមានតាហុងហ្នឹង អញ្ចឹងបងសា រឿន គាត់ចាំបញ្ជាពីតាហុងហ្នឹងដែរ ។

ដានី ៖ អ្ហូ!

ហឿន ៖ បាទ!ជាមនុស្សសំខាន់របស់ថ្នាក់លើគេម៉ោនៅណា៎ ។

ដានី ៖ ចុះ អៀង សារី គាត់ធ្លាប់ម៉ោទេ?

ហឿន ៖ បាទ!យូរៗ ច្រើនឆ្នាំណាស់បានគាត់ម៉ោមួយដង ជួនកាល២-៣ឆ្នាំអីបានម៉ោ ។

ដានី ៖ ២-៣ឆ្នាំ បានម៉ោ?

ហឿន ៖ បាទ!

ដានី ៖ គាត់ម៉ោជួបនិយាយជាមួយកងទ័ពអីហ្នឹង?

ហឿន ៖ បាទ!បើយើងបើសិក្ខាសិលាជាថ្នាក់ជាតិរបស់កម្ពុជាប្រជាធិបតេយ្យហ្នឹង គាត់ច្រើនតែយកហៅតែមេៗទាំងអស់ទៅប្រជុំនៅកន្លែងគាត់ធម្ម១០០ទៅ៨៥វិញ ។

ដានី ៖ ទៅកន្លែងដីថៃវិញនៅធម្ម១០០ហ្នឹង?

ហឿន ៖ បាទ!

ដានី ៖ ខាងធម្ម១០០ខាងធម្ម៨៥?

ហឿន ៖ បាទៗ!

ដានី ៖ បាទ!ចុះអៀង សារី កាលហ្នឹងគាត់គ្រប់គ្រងទិសខាងណាវិញ?

ហឿន ៖ អៀង សារី គាត់ទិសយើងហ្នឹងឯង ស៊ីសុផុនខាងត្បូង ស៊ីសុផុនខាងជើង អៀង សារីគាត់គ្រប់គ្រងកាន់កាប់ ។

ដានី ៖ ខាងជើង ខាងត្បូងគាត់ទាំងអស់?

ហឿន ៖ បាទ!

ដានី ៖ ប៉ៃលិន ម៉ាឡៃ ខាងស្វាយចេក ខាងថ្មពួកហ្នឹងគាត់គ្រប់គ្រងទាំងអស់?

ហឿន ៖ បាទ!អៀង សារី ។

ដានី ៖ បាទ!ហើយកាលហ្នឹងពូមានតួនាទីធ្វើអីដែរ?

ហឿន ៖ បាទ!ខ្ញុំៗនៅកាន់ជាវរសេនារង វរសេនាធំ នៅវរៈសេនាធំ១០៥ហ្នឹង ។

ដានី ៖ អញ្ចឹងពូអនុវរសេនាធំ?

ហឿន ៖ បាទ!

ដានី ៖ ទទួលខាងអី កាលហ្នឹង?

ហឿន ៖ បាទ!ខាងការងារយោធាម៉ង ។

ដានី ៖ ការងារយោធានៅសមរភូមិរហូត?

ហឿន ៖ នៅសមរភូមិរហូត ។

ដានី ៖ អ្ហូ!

ហឿន ៖ ប៉ុនមិនសូវបានទៅថៃទៅអីទេ ។

ដានី ៖ ចុះខស្សាហ៍ទៅប្រជុំជាមួយមេៗទេ?

ហឿន ៖ បើទៅៗតែរយៈពេលប្រជុំ២ខែ-៣ខែហ្នឹង ម៉ោវិញហើយ ម៉ោត្រាំត្រែងនៅនេះរហូតទៅ ។

ដានី ៖ ចុះពូកាន់អនុវរហ្នឹងតាំងពីពេលណាម៉ោ ឡើងអនុវរកងធំហ្នឹង?

ហឿន ៖ បាទ!ខ្ញុំឡើងតាំងពីឆ្នាំ៨៦-៨៧ហ្នឹងម៉ោ ។

ដានី ៖ បាទ!កាលពីដំបូងមុនពូកាន់វរសេនាតូច?

ហឿន ៖ បាទ!ពីមុនម៉ោខ្ញុំកាន់វរសេនាតូច ក្នុងចំរុះរបស់វរសេនាធំ១០៥ហ្នឹង បានក្រោយម៉ោឈនគេឡើងវរសេនាធំ៤០៥ដែលហ្នឹង ។

ដានី ៖ បាទ!ពូ១០៥ឬ៤០៥?

ហឿន ៖ ៤០៥ វរសេនាតូច៣៥០ ។

ដានី ៖ ប្រធានវរគាត់ឈ្មោះ ឈន?

ហឿន ៖ ប្រធានវរ ។

ដានី ៖ ប្រធានវរសេនាធំ៤០៥?

ហឿន ៖ បាទ!ឈន ហ្នឹងឯាប់បាត់ហើយ ។

ដានី ៖ ចុះកាលហ្នឹងអ៊ើ!ពូដូចថាពេលហ្នឹងយាំងម៉េចដែរ ដូចថាវររបស់ពូនៅចំទិសខាងណាទៅ នៅចំទិសខាងណា?

ហឿន ៖ ខ្ញុំនៅចំដីនេះឯង នៅចំដីស្វាយចេក ខាងភ្នំស្រុក ។

ដានី ៖ ខាងផ្នែកស្វាយចេក ខាងភ្នំស្រុក?

ហឿន ៖ បាទ!បើគិតទៅវា៣-៤ស្រុកណ៎ុះកាលហ្នឹង ជាការបែកចាយគ្រប់គ្រងដឹកនាំវ៉ៃ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ព្រោះខ្ញុំទទួលដីធំដែរ ។

ដានី ៖ អ្ហូ!អញ្ចឹង?

ហឿន ៖ បាទ!

ដានី ៖ អញ្ចឹងវររបស់ពូនៅទិសខាងហ្នឹងបណ្ដោយ?

ហឿន ៖ បាទ!

ដានី ៖ ចាប់ពីឆ្នាំណាម៉ោដែលពូទទួលខុសត្រូវហ្នឹង?

ហឿន ៖ វាឆ្នាំតាំងពីយើងបែកជំរុំ ៨៣-៨៤ហ្នឹងម៉ោ យើងចុះម៉ោនៅហ្នឹងម៉ោ ៨៣-៨៤ យួនវ៉ៃបែកជំរុំ៨៣ ៨៤យើងចុះម៉ោនៅខាងក្នុងវិញ ចុះពង្រីកកម្លាំងតស៊ូវ៉ៃខាង ក្នុង ។

ដានី ៖ ម៉ោនៅខាងស្វាយចេក ថ្មពួកហ្នឹង?

ហឿន ៖ បាទ!

ដានី ៖ ណាទៀតតែ២ហ្នឹងទេ?

ហឿន ៖ ភ្នំស្រុក ។

ដានី ៖ ភ្នំស្រុក?

ហឿន ៖ បាទ!

ដានី ៖ អញ្ចឹងខាងវរសេនាធំ៤០០ទទួលខាងណាខ្លះ?

ហឿន ៖ បើទៅខាងនេះវាចូល៤០១គេគ្រប់គ្រងដែរ ។

ដានី ៖ ខាងណា?

ហឿន ៖ ខាងថ្មពួក ។

ដានី ៖ ខាងថ្មពួក?

ហឿន ៖ បាទ!ម៉ាចំហៀងម្នាក់ថ្មពួក ស្វាយចេកខាងលិច ខាង៤០១វរសេនាធំ៤០១ដែរ ។

ដានី ៖ ៤០១?

ហឿន ៖ បាទ!គេបែកមកកំណាត់ៗម្នាក់ទៅ ប៉ុនដល់ពេលដែលត្រូវយើងអាចជួបជុំគ្នាចំរុះសហការគ្នាយកកម្លាំងសាច់ដុំវ៉ៃ ត្រូវវ៉ៃទីតាំងអីណា។

ដានី ៖ បាទ!ចុះកាលហ្នឹងយើងវ៉ៃគ្នាម៉េចទៅ ដូចថាខាងនោះកាលហ្នឹងមានប៉ាវ៉ាផង?

ហឿន ៖ បាទ!អាហ្នឹងប៉ាវ៉ារឿងរបស់គេផ្សេងទេ គេម៉ោចំរុះជាមួយយើង គេសហការជាមួយយើងបាន គេមិនសហការជារឿងរបស់គេ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ប៉ុន្តែយើងមិនមានអីទមោនស្បូជាមួយពួកហ្នឹងទេ ព្រោះកម្លាំងរបស់ត្រីភាគីណា។

ដានី ៖ បាទៗ!

ហឿន ៖ ពួកគេមាននយោបាយទូត នយោបាយជាតិ អន្តរជាតិរបស់គេដែរ។

ដានី ៖ បាទ!ចុះខាងប៉ាវ៉ាគេនៅខាងណាទៅម៉្តុំណា?

ហឿន ៖ បាទ!គេនៅចុះចំរុះខេត្តពីណាពីណី ចុះកន្លែងណាដែលមានសុវត្ថិភាពគេចុះ ម៉ោតាមតែយើង តាមភូមិតាមអីហ្នឹងព្រោព្រាតទាំងអស់។

ដានី ៖ ប៉ុន្តែទិសខាងស្វាយចេក ខាងថ្មពួក ភ្នំស្រុកអីហ្នឹង ខាងប៉ាវ៉ាអាំ?

ហឿន ៖ វាមានដូចគ្នា។

ដានី ៖ មានដូចគ្នាដែរ?

ហឿន ៖ បាទ!

ដានី ៖ អាហ្នឹងកងពលអីដែរ ខាងប៉ាវ៉ា?

ហឿន ៖ អូរច្រើនណាស់កងពលអីខ្លះទេ តាំងពី ដេ សង់ឌី តាំងពីកងពល១០៨ កងពល ១០៦ កងពលអីណាទៀតច្រើនណាស់។

ដានី ៖ បាទ!ពីណាគេប្រធានខាងប៉ាវ៉ាហ្នឹង គ្រប់គ្រងកម្លាំងខាងប៉ាវ៉ា?

ហឿន ៖ បាទ!នេះ ខូ អៀ នេះ ប្រធានតំបន់ធំគេ ខូ អៀៗនៅអភិបាលខេត្តរងនៅបន្ទាយមានជ័យយើងសព្វថ្ងៃនេះ។

ដានី ៖ ឈ្មោះអីគេ ខូ អៀ?

ហឿន ៖ ខូ អៀៗ។

ដានី ៖ គាត់ខាងប្រធានធំគេ គាត់ប្រធានតំបន់ខាងនេះ?

ហឿន ៖ បាទ!ប្រធានតំបន់ដីយើងនេះ។

ដានី ៖ បាទ!ខាងប៉ាវ៉ា?

ហឿន ៖ ប៉ាប៉ា ។

ដានី ៖ ចុះអ៊ី?

ហឿន ៖ សូរ ចាន់ហេង ។

ដានី ៖ សូរ ចាន់ហេង?

ហឿន ៖ សូរ ចាន់ហេងដែលប្រធានកងពល៥១សព្វថ្ងៃនេះ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!គេរង ហូ ឆៀ ហ្នឹងគាត់ប្រធាន ។

ដានី ៖ បាទ!ចុះញ៉ឹក ប៊ុនឆៃគាត់?

ហឿន ៖ ញ៉ឹក ប៊ុនឆៃគាត់ជាTPខាងវណ្ណៈរិទ្ធិ ។

ដានី ៖ ខាងវណ្ណៈរិទ្ធិទេ?

ហឿន ៖ ជាគណបក្ស ។

ដានី ៖ ប៉ាប៉ាមាន២ទៀតកាលហ្នឹង?

ហឿន ៖ មាន២-៣នោះ ។

ដានី ៖ ៣បក្សទៀត?

ហឿន ៖ បាទ!មានអាដឺរីក្បាល៣ មានអាដឺរីក្បាល១ មានអាស៊្មីណានោះ បក្សវាច្រើន ។

ដានី ៖ បាទ!អញ្ចឹងប៉ាប៉ាដូចថា ខូ ឆៀ ហើយនឹង ចាន់ ហេង គាត់នៅខាងណា?

ហឿន ៖ ខាង សឺន សាន ។

ដានី ៖ សឺន សាន?

ហឿន ៖ បាទ!ហើយខាងមួយទៀតនោះខាង អ៊ុត សាខម ខាងអី ។

ដានី ៖ ខាងសាក់ សុខន?

ហឿន ៖ បាទ!អាដឺរីក្បាល៣គេនោះ ។

ដានី ៖ មាននៅហ្នឹងដែរ?

ហឿន ៖ បាទ!នៅហ្នឹងដែរ ហើយបន្ទាប់មកខាងTPនេះ ខាង ញ៉ឹក ប៊ុនឆៃ ខាងវណ្ណៈរិទ្ធិនេះ ។

ដានី ៖ បាទ!ហ្នឹងមាននៅក្នុងហ្នឹងដែរ?

ហឿន ៖ មាននៅហ្នឹងដែរ វាច្របូកច្របល់គ្នា ចំរុះ ។

ដានី ៖ តែលោក ញ៉ឹក ប៊ុនឆៃទិសគាត់នៅហ្នឹងដែរឬអត់ទេ?

ហឿន ៖ វាកន្ទ័ពវានៅក្នុងហ្នឹងដូចគ្នា តែមេៗវានៅតែក្រោយទេ នៅលើភ្នំនៅលើណាៗ យូរៗម៉ោ១ដងណា៎ ។

ដានី ៖ បាទ!តែជួបជាមួយពួកគាត់ដែរ?

ហឿន ៖ បាទ!ត្រូវប្រជុំត្រូវវៃទីតាំងធំៗអី គេម៉ោសុំសហការជាមួយយើង សុំមេៗយើងអញ្ចឹង ។

ដានី ៖ បាទ!

ហឿន ៖ បាទ! មេៗយើងរៀបចំចំរុះគ្នាត្រូវវៃម៉េចៗ ។

ដានី ៖ ទីហ្នឹងដូចថាកាលហ្នឹងខាងទាហានរដ្ឋកម្ពុជាហ្នឹងគេនៅដែរ?

ហឿន ៖ តំបន់នេះគេហៅថាជាតំបន់ប្រទង់ប្រទាញ ។

ដានី ៖ ប្រទាញប្រទង់?

ហឿន ៖ បាទ!ដូនកាលខ្ញុំនៅ ដូនកាលគេនៅ ។

ដានី ៖ អូ!អញ្ចឹង?

ហឿន ៖ បាទ!ថ្ងៃណាគេប្រមូលគ្នាបានច្រើនគេឡើងម៉ោវៃគេយកទៅ បាទ!ថ្ងៃណាខ្ញុំប្រមូលបានខ្ញុំវៃវិញទៅ ទៅវិញទៅ ព្រោះតំបន់ហ្នឹងទ្រង់ប្រទាញ អត់មានអ្នកណាកាន់កាប់បាន ។

ដានី ៖ ចុះកន្លែងស្រុកស្វាយចេក?

ហឿន ៖ ស្វាយចេកហ្នឹងរបស់គណបក្សប្រជាជនហើយ អាហ្នឹងគេនៅហើយ ។

ដានី ៖ របស់រដ្ឋកម្ពុជា?

ហឿន ៖ រដ្ឋកម្ពុជាគេនៅមើងមាត់ហើយ ប៉ុនអាហ្នឹងគេមើងអីបើយើងវៃបែកប៉ុន្មានដងហើយ ។

ដានី ៖ វៃបែកប៉ុន្មានដងដែរ យើងវៃយកស្រុកបានដែរ?

ហឿន ៖ បាទ!យើងវៃយកបន្ទាយមានជ័យដែលហ្នឹង ។

ដានី ៖ ឆ្នាំណាដែលយើងវៃ?

ហឿន ៖ វៃឆ្នាំ៨៩-៨៨ហ្នឹង ។

ដានី ៖ ឆ្នាំ៨៩-៨៨វៃចេញម្តងៗដែរ?

ហឿន ៖ បាទ!ពួកថ្មពួកអីយើងវៃបានអស់ហើយ ។

ដានី ៖ កាលហ្នឹងខាងរដ្ឋកម្ពុជាពីណាគេប្រធានគណៈគ្រប់គ្រង?

ហឿន ៖ អូ!ខ្ញុំអត់ច្បាស់គេដែរ ពួកតាឡុញពួកអីហ្នឹងជាអ្នកអធិរាជនៅជិតត្រង់ហ្នឹងដែរ ។

ដានី ៖ តាឡុញ?

ហឿន ៖ បាទ!ហើយមេៗច្រើនទៀត មានដកពីកំពង់ចាមយកមកនៅហ្នឹង។

ដានី ៖ មេកងពល?

ហឿន ៖ ខ្ញុំភ្លាប់អត់បានទេពួកហ្នឹង មែនទែនទៅពីដើមខ្ញុំមានកំណត់ហេតុអី ខ្ញុំចុះក្នុងបញ្ជីអីតាមដានអញ្ចឹងដែរ ហើយក្រោយម៉ោយើងត្រូវគ្នាខ្ញុំប្រមូលដុតចោលអស់ទៅ។

ដានី ៖ អ្ហូ!

ហឿន ៖ កុំអីឯកសារខ្ញុំមិនខ្វះទេ ស្អីៗអ្នកណាគេស្អីៗ ហ៊ុន សែន ទៅពឹងអាណាណាអីឲ្យជួយអាណាអាណី លុយជំពាក់អាណាអាណីអីកាលនោះមេៗ កាលនោះខ្ញុំកត់ទុក ដើម្បីយកទៅប្រជុំផ្សព្វផ្សាយឲ្យប្រជាពលរដ្ឋយើងដឹងដែរ។

ដានី ៖ បាទ!

ហឿន ៖ ពីការប្រព្រឹត្តរបស់អ្នកទាំងឡាយធ្វើខុសធ្វើត្រូវអីណា។

ដានី ៖ បាទៗ!

ហឿន ៖ បាទ!ដល់យើងត្រូវគ្នា ខ្ញុំមិនទុកឯកសារហ្នឹងឲ្យគេចាប់បានទេ អញ្ចឹងខ្ញុំប្រមូលដុតចោលទាំងអស់ទៅ ខ្ញុំថាវាអត់បានការ។

ដានី ៖ ចុះពូកាលនោះពូរៀបការឆ្នាំណា រៀបការជាមួយមីង?

ហឿន ៖ កាលនោះខ្ញុំរៀបការឆ្នាំ៨៥ ដែលខ្ញុំនៅនេះហើយ។

ដានី ៖ ពេលទៅជំរុំ៨៥ឬអត់?

ហឿន ៖ បាទ!ឆ្នាំ១៩៨៥ហ្នឹង។

ដានី ៖ ៨៥?

ហឿន ៖ បាទ!

ដានី ៖ បាននៅនេះឬទៅនោះហើយ?

ហឿន ៖ បាននេះទៅនោះ ការពិតទៅមែនទែនទៅរឿងនេះចេះទេ យើងស្រឡាញ់គ្នានេះ នាងគេមានប្អូនមួយឈ្មោះ ប៊ុន ធឿន វាឈឺ ដល់ឈឺអញ្ចឹងទៅ ខ្ញុំថាឲ្យនាំវាយកទៅពេទ្យយកទៅអីអញ្ចឹងទៅ ខ្ញុំឲ្យមនុស្សខ្ញុំហ្នឹងចូលយកពីជំរុំថ្មីហ្នឹងម៉ោ ពីកន្លែងបារាំងហ្នឹង ទៅយកម៉ោប៉ុនបានគ្នានៅបឹងត្រកួននេះទៅ។

ដានី ៖ នៅបឹងត្រកួន?

ហឿន ៖ បាទ!

ដានី ៖ មីងគាត់ធ្វើអីកាលហ្នឹង?

ហឿន ៖ គេធ្វើប្រធានសមាគមន៍ឃុំផ្តាំហ្នឹង ។

ដានី ៖ ប្រធានសមាគមន៍ឃុំផ្តាំ?

ហឿន ៖ បាទ!របស់គណបក្សប្រជាជនឲ្យអូសទាញខ្មែរក្រហមខ្មែរអីហ្នឹង ។

ដានី ៖ គាត់អ្នកនៅក្នុងស្រុកទេអញ្ចឹង ?

ហឿន ៖ បាទ!គាត់អ្នកនៅក្នុងស្រុក ។

ដានី ៖ អ្អូ!

ហឿន ៖ គាត់អ្នកធ្វើមេអូសទាញខ្មែរក្រហមចូលស្រុកវិញ ។

ដានី ៖ អ្អូ!

ហឿន ៖ ដល់អូសគេមិនបានទៅខ្លួនឯង ។

ដានី ៖ អ្អូ!អូសគេមិនបានទៅខ្លួនឯង?

ហឿន ៖ ហ្នឹងហើយ ។

ដានី ៖ បាទ!ដល់អញ្ចឹងទៅ ហង់ ពិន យ៉ាងម៉េចដែរ ពូដឹងរឿងគាត់យ៉ាងម៉េចដែរ?

ហឿន ៖ បាទ!ពិនហ្នឹងខ្ញុំដឹងត្រឹមនេះទេ ដែលខ្ញុំដឹងៗត្រឹមបង ឌុល សារឿន យកមកផ្ញើរខ្ញុំ ។

ដានី ៖ ឌុល សារឿន?

ហឿន ៖ បាទ!ព្រោះខ្ញុំនៅដីនេះ គាត់យកមកផ្តាំផ្ញើរខ្ញុំណា៎ ។

ដានី ៖ បាទ!

ហឿន ៖ សូមឲ្យឯងមើលគាត់ផង គាត់ជាមនុស្សរបស់ថ្នាក់លើ ជាមនុស្សសំខាន់របស់ថ្នាក់លើណា៎ ។

ដានី ៖ បាទ!

ហឿន ៖ ហើយគេមានគោលការណ៍នយោបាយត្រូវ បើសិនជានៅនេះដូចថាប្រកសេដ្ឋកិច្ចល្អ ណា៎ ។

ដានី ៖ បាទ!

ហឿន ៖ គាត់នឹងរៀបចំធ្វើរោងចក្រនៅទីនេះ គាត់ថាទី១ ធ្វើរោងចក្រខ្មៅធ្វើបារី ទី២ធ្វើរោងចក្រស្ករស ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ហើយនឹងរោងចក្រអារឈើអារអីអញ្ចឹងណា៎ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!អញ្ចឹងយើងនៅបន្តើតនៅអីទៅ ខាងលើគេត្រូវឲ្យសំភារៈឲ្យអីយើងធ្វើ ព្រោះយើងឈប់ប្រកួតប្រជែងខាងយោធាហើយ យើងគិតនយោបាយសេដ្ឋកិច្ចវិញ ។

ដានី ៖ អ្ហូ!

ហឿន ៖ អញ្ចឹងគេមាននយោបាយទាក់ទាញខាងសេដ្ឋកិច្ចដែរ ។

ដានី ៖ បាទ!

ហឿន ៖ ដល់ក្រោយម៉ោយើងត្រូវគ្នា៩១ហ្នឹង ៩៣យើងបោះឆ្នោតអីៗហ្នឹង ខ្មែរក្រហមមិនចូលរួមការបោះឆ្នោតឆ្នាំ៩៣ហ្នឹង ។

ដានី ៖ ចុះនៅនេះមានបានបោះដែរ?

ហឿន ៖ បោះៗ!ពួកខ្ញុំទាំងអស់គ្នាមិនបានចូលរួមជាបេក្ខជនបោះឆ្នោតក៏ពិតមែន ប៉ុន្តែប្រមែរប្រមូលគ្នាទៅជួយបោះឆ្នោតឲ្យ ពួកប៉ាវ៉ាហ្នឹងម៉ាពួករណសិរ្សិហ្នឹង ។

ដានី ៖ បាទ!

ហឿន ៖ ឲ្យទៅគាំទ្រស្តេច ។

ដានី ៖ បាទ!

ហឿន ៖ ដល់ពេលគេបោះឆ្នោតឈ្នះទៅ គេមិនបានយកពួកខ្មែរក្រហមហ្នឹងចូលក្នុងជួរគេ ទៅពង្រឹងរដ្ឋអំណាចសម្រាប់ឈ្នះអីជារបស់គេ ជាកម្លាំងរបស់គេ ជាបក្សគេហ្នឹង គេរួម គ្នាដឹកស្រាវរួមគ្នាជាមួយគណបក្សប្រជាជនទៅវ៉ៃខ្មែរក្រហមវិញ ។

ដានី ៖ បាទ!

ហឿន ៖ ទៅចេះវិញ ដកអាវុធខ្មែរក្រហមទៅវ៉ៃខ្មែរក្រហមទៅ បានខ្មែរក្រហមនេះវាទៅជាខឹងគ្នាឯងវិញដែរ អាកាលនៅព្រៃរួមរស់តស៊ូជាមួយគ្នា ដេកធ្លាប់នៅព្រៃអត់អីស៊ី ជាមួយគ្នាចែកគ្រាប់គ្នាបាញ់ ទៅជាទៅវ៉ៃអ្នកតស៊ូគ្នាឯងទៅវិញ ។

ដានី ៖ បាទ!

ហឿន ៖ អញ្ចឹងយើងកុំទៅចូលជាមួយអាពួកនេះ ទៅចូលយួនទៅវិញទៅ ចូលគណៈបក្សហ្នឹងតែម្តងទៅ ។

ដានី ៖ បាទ!

ហឿន ៖ បាទ! វាពូកែជាង ។

ដានី ៖ បាទ!

ហឿន ៖ កាលនោះយើងថាអញ្ចឹង ដូចថាយើងនិយាយទៅថាយើងបន្ទោសបន្ទាប់គេ យើងថា អស់បើយើងទៅចូលអាយ៉ងយួនវាពិបាកណាស់ យើងចូលយួនវិញទៅ វាពូកែដាង វាចាំដាង វាច្រើនជាងអាយ៉ងទៅទៀត បានគ្នាបុកចូលអញ្ចឹងវិញទៅ បានបែកអ្នក គស្ទូទៅគាំទ្រពួកគណៈប្រជាជនវិញ ។

ដានី ៖ បាទៗ!

ហឿន ៖ អញ្ចឹងគណៈបក្សប្រជាជនគេគាំទ្រ ខ្មែរក្រហមម៉ឺងម៉ាត់ អញ្ចឹងទៅ រហូតមកទល់សព្វថ្ងៃហ្នឹងមានបែកការងារធ្វើអីណាណើអញ្ចឹងទៅ បាននៅក្នុងជួររដ្ឋអំណាចគេជាមួយគ្នាអញ្ចឹងទៅ ។

ដានី ៖ បាទ!ចុះអ៊ីពូតា ពិត គាត់ម៉ោដូចថា ឌុល សារឿន គាត់យកមកធ្វើរជាមួយពូហ្នឹង តើឆ្នាំណា?

ហឿន ៖ ឆ្នាំ...កាលនោះ៩៣ហ្នឹងឯង ។

ដានី ៖ ៩៣?

ហឿន ៖ ៩២-៩៣ហ្នឹង ។

ដានី ៖ មុនបោះឆ្នោត?

ហឿន ៖ ៩២ទេ មុនបោះឆ្នោត១ឆ្នាំហ្នឹង ៩២-៩៣ហ្នឹង ព្រោះយើងបោះឆ្នោត៩៣ ហ្នឹង ហើយថាវា១ឆ្នាំចុះ ។

ដានី ៖ កាលហ្នឹងយ៉ាងម៉េចតា ពិន គាត់ម៉ោពីកន្លែងណាបើតាមពូជួបគាត់ដំបូង?

ហឿន ៖ បាទ!ខ្ញុំបានជួបគាត់ គាត់ម៉ោពីធម្ម១០០ ម៉ោពីកន្លែងមេរបស់ ប៉ុល ពត ម៉ោតា នួន ជា ម៉ោពីអីហ្នឹង ។

ដានី ៖ ឌុល សារឿន គាត់ប្រាប់ថាខាងថ្នាក់លើគេយកធ្វើរអញ្ចឹងម៉ោ មនុស្សរបស់ថ្នាក់ លើ?

ហឿន ៖ បាទ!ជាមនុស្សរបស់ថ្នាក់លើ គាត់យកមកធ្វើរទុកដាក់ឲ្យគេការពារផ្នែកសន្តិសុខឲ្យ គាត់ ។

ដានី ៖ អ្ហូ!

ហឿន ៖ ក្រែងមានអ៊ើ!កាលនោះវារយ៉ាវយ៉ៃដែរ ក្រែងមានក្រុមខូចព្យាបាទគាត់ ។

ដានី ៖ អ្ហូ!បាទៗ ចុះម៉េចឲ្យគាត់ចូលមកនៅស្រុក ។

ហឿន ៖ បាទ?

ដានី ៖ ចុះកាលហ្នឹងធ្វើរគាត់ ក្រែងកាលហ្នឹង៩២អីហ្នឹងពូអីនៅព្រៃនៅឡើយទេ?

ហឿន ៖ បាទ!យើងមានការផ្សះផ្សាជាតិ បង្រួបបង្រួមជាតិ ត្រូវគ្នាតាំងពី៩១មកម៉្លេះ ។

ដានី ៖ បាទ!តាំងពីឆ្នាំ៩១ ។

ហឿន ៖ បាទ!តាំងពីជួបនៅបារីសនោះណា ។

ដានី ៖ បាទៗ!៩១ ។

ហឿន ៖ បាទ!៩១ម៉ោយើងត្រូវគ្នា ។

ដានី ៖ បាទ!

ហឿន ៖ អញ្ចឹងយើងត្រូវគ្នា មានដំណោះស្រាយឈប់បាញ់គ្នា មានគោលការណ៍៥ខ ។

ដានី ៖ បាទ!

ហឿន ៖ មិនចឹង?

ដានី ៖ បាទៗ!

ហឿន ៖ ខអីៗខ្លះទេ ខ្ញុំមិនចាំមិនច្បាស់ ធ្លាប់ពីដើមខ្ញុំកត់ទុកស្រួលបួល ទី១ៈបញ្ឈប់ការបាញ់គ្នាអញ្ចឹងទៅ ហើយទី២ទៀតៈរៀបចំប្រមែរប្រមូលកង៏ទ័ពចូលមណ្ឌលដកអាវុធ៥០ភាគរយ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ទី៣ៈ អ៊ីស្អីៗទេ យួនដកកង៏ទ័ពចេញដោយគ្មានលក្ខ័ណ្ឌហ្នឹង ទី៤ហ្នឹងយើងបង្កើតជាក្រុមប្រឹក្សាជាតិជាន់ខ្ពស់៤ភាគី ។

ដានី ៖ អ្ហូ!បាទៗ ។

ហឿន ៖ បាទ!សម្រាប់ដើរត្រួយពិនិត្យគ្រប់តំបន់គ្រប់ទិសទីនោះណ៎ា ។

ដានី ៖ បាទៗ!

ហឿន ៖ ទៅតាមការបោះឆ្នោតអញ្ចឹងទៅ ។

ដានី ៖ បាទៗ!

ហឿន ៖ វាចប់ត្រឹមកន្លែងបោះឆ្នោត ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ដល់ ប៉ុល ពត នោះគាត់មើលឃើញថា យួនវាប្រែ គ្រាន់តែប្រែ អានេះគ្រាន់តែរូបរាងពីយោធាម៉ោស៊ីវិល អញ្ចឹងគាត់ថា នៅតែចាញ់យួនដដែលវាអត់ឈ្មះយួន ទេ អញ្ចឹងមិនបោះឆ្នោតទេ គាត់បែរជាចង់វៃវិញទៀត ។

ដានី ៖ បាទ!

ហឿន ៖ វ៉ៃដើម្បីឲ្យគេខ្លាចខាងយោធាគេចូលតុចរចារជំលោះបញ្ហាហ្នឹងឲ្យទៅជាស័យប្រវត្តិ ប៉ុន ដល់វាមិនទៅ ដល់មិនទៅ ទៅតែខ្លួនគាត់ហ្នឹង អ្នកទៅវិញ(សើច) វាខុសដដែល ។

ដានី ៖ បាទ!

ហឿន ៖ អញ្ចឹងគាត់វិភាគគ្រោងទុក ពួកហ្នឹងនយោបាយគាត់ខ្លាំងដែលហ្នឹង ជ្រៅណាស់ ប៉ុនអ៊ី យើងធ្វើមិនបាន ធ្វើមិនដូចគាត់ ។

ដានី ៖ បាទ!អញ្ចឹងពេលហ្នឹង តា ពិន ហ្នឹង គេដាក់ខាងថ្នាក់លើដាក់ម៉ោ ក្រោយម៉ោប្រុងឲ្យ រៀបចំយ៉ាងម៉េចបើតាមពូដឹង?

ហឿន ៖ បាទ!គាត់ច្រើនតែថាជាមនុស្ស របស់ថ្នាក់លើអីៗអញ្ចឹងទេ ដើម្បីខាងលើគេទុកចិត្ត ហ្នឹង ស្រេចនឹងគាត់ហ្នឹង គាត់ត្រូវសុំធ្វើអី ព្រោះលុយថ្នាក់លើគេមានលុយមិនចឹង?

ដានី ៖ បាទ!

ហឿន ៖ បាទ!អញ្ចឹងគាត់ត្រូវធ្វើអីច្រកហ្នឹងអាចបើកជាសេដ្ឋកិច្ច បើស្អីបាន ធ្វើស្អីបាន អញ្ចឹង បើកតាមរយៈគាត់ ។

ដានី ៖ តាមរយៈអ៊ុ...?

ហឿន ៖ រយៈតា ពិន ហ្នឹង ។

ដានី ៖ អ៊ូ!កាលហ្នឹងគេប្រាប់ថាឈ្មោះថាម៉េច?

ហឿន ៖ គាត់ប្រាប់ថាឈ្មោះ តាពិនៗធម្មតា ហើយខ្ញុំអត់ដឹងថាគាត់ហ្នឹង មានជីវប្រវត្តិ មេគុកទួលស្លែងអីណាណីទេ ខ្ញុំអត់ដឹងដែលទេ ។

ដានី ៖ អ៊ូ!ដឹងតែឈ្មោះ ហង់ ពិន អញ្ចឹង?

ហឿន ៖ ដឹងតែត្រឹមថាឈ្មោះ ហង់ តាពិនៗ ។

ដានី ៖ តាពិន?

ហឿន ៖ បាទ! រហូតដល់គាត់ប្រាប់ខ្ញុំថា គាត់គ្រោះទ្រូងប្រាប់ខ្ញុំថាគាត់ហ្នឹងទៅជាស្គាល់អី ស្គាល់ៗតាឌុច គាវតឹមអាវហ្នឹងស្គាល់ទេ ខ្ញុំថាអត់ស្គាល់ទេ គាត់ទះទ្រូងលេងអញ្ចឹង ណា៎ ។

ដានី ៖ ពីអន្លាល់ៗ?

ហឿន ៖ កាលយើងសម័យហ្នឹង គាត់នៅហ្នឹងឯង ។

ដានី ៖ គាត់ប្រាប់ដែរ គាត់ថាគាត់ថាគាត់ឈ្មោះឌុច?

ហឿន ៖ គាត់ប្រាប់ខ្ញុំដែរ ប៉ុន្តែខ្ញុំអត់ចាប់អារម្មណ៍គាត់ហ្នឹងជាមេគុកទួលស្លែងទេ ព្រោះកន្លែងមជ្ឈមខ្ញុំអត់ដឹងទេ ។

ដានី ៖ គាត់ប្រាប់ថាគាត់ឈ្មោះ ឌុច ឈ្មោះ កាំង គាវអាវ តើស្គាល់គាត់ឬអត់?

ហឿន ៖ បាទ!គាត់សួរថាស្គាល់គាត់ឬអត់?

ដានី ៖ គាត់ប្រាប់តែពូម្នាក់ ឬប្រាប់អ្នកផ្សេងៗដែរ?

ហឿន ៖ អត់ទេ!ប្រាប់តែខ្ញុំទេ ។

ដានី ៖ ហេតុអីបានគាត់ប្រាប់តែពូ?

ហឿន ៖ គាត់ក្រែងថាខ្ញុំធ្វើមេយូរដែរ ក្រែងខ្ញុំដឹងរឿង ។

ដានី ៖ អ្ហូ!

ហឿន ៖ ប៉ុន្តែខ្ញុំអត់ដឹងរឿង ។

ដានី ៖ អ្ហូ!អត់ដឹងរឿង?

ហឿន ៖ បាទ!អាមជ្ឈមហ្នឹង ។

ដានី ៖ គាត់ចង់ដឹងសាកមើល?

ហឿន ៖ គាត់ចង់សាកមើល ព្រោះតែឈ្មោះហ្នឹង យើងគិតថាមនុស្សនេះមិនធម្មតារួចទៅហើយ ។

ដានី ៖ អ្ហូ!

ហឿន ៖ ព្រោះមនុស្សរបស់ថ្នាក់លើ ហើយគាត់មនុស្សជាអ្នកចេះ មិនចឹង ។

ដានី ៖ តែពូថាអត់ដឹងអត់ស្គាល់?

ហឿន ៖ ខ្ញុំអត់ដឹង ព្រោះខ្ញុំអត់ដែលដឹង ។

ដានី ៖ ដល់អញ្ចឹងគាត់ម៉េចទៀតទៅ?

ហឿន ៖ ដល់អញ្ចឹងគាត់ថាមិនបាច់ដឹងទេ ប្អូនឯងមិនបាច់ដឹងទេ បានគាត់ចេះតែនិយាយលេងគាត់ទៅរៀនស្រុកចិន ទៅរៀនអីណាណី ខ្ញុំចូលចិត្តទៅអង្គុយលេងជាមួយគាត់ដែរ ។

ដានី ៖ បាទ!

ហឿន ៖ ទៅរៀនស្រុកចិនគាត់សន្សំលុយ បានលុយចេះចុះអីខ្លះដែរ ក្រោយម៉ោគាត់និយាយប្រាប់គេឯងផ្សេងទៀតទៅ បែករឿងថាគាត់មានមាសប៉ុន្មានគីឡូ ចោរប្លន់គាត់ ដែលថាត្រូវស្លាប់នោះ ។

ដានី ៖ គាត់ប្រាប់គេថាគាត់មានមាស?

ហឿន ៖ បាទ!គាត់ទៅរៀននៅស្រុកចិន ថាគាត់ហ្នឹងមានមាសពាគីឡូ ។

ដានី ៖ បាទ!

ហឿន ៖ គាត់មានមាសមែន មិនអត់ទេ! នាឡិកាទីតានី នាឡិកាស្អីៗមានរបស់គាត់ ។

ដានី ៖ អញ្ចឹងពេលដែលចោរប្លន់ហ្នឹង ដោយសារតែល្បីថាគាត់មានមាសមានអីហ្នឹងបានប្លន់?

ហឿន ៖ បាទ!រឿងចោរប្លន់ហ្នឹង ប្លន់យកមាសយកប្រាក់ទេ ។

ដានី ៖ អញ្ចឹងដែលឆ្នាំ៩២ ឆ្នាំដែល ឌុល សារឿន យកមកធ្វើរពូហ្នឹង ឲ្យគាត់មកនៅហ្នឹងចុះមានទំនាក់ទំនងអីទៀតឬអត់?

ហឿន ៖ បាទ!ដល់អញ្ចឹងទៅបានអ៊ីគាត់ហ្នឹង យកឈ្មោះធ្វើជាគ្រូ ធ្វើជាអីគេរៀបចំគាត់ជាអ្នកចេះ ឲ្យធ្វើគ្រូបង្រៀនធ្វើអីទៅ ។

ដានី ៖ បាទ!

ហឿន ៖ គាត់បង្រៀននៅនេះបានប៉ុន្មានឆ្នាំហ្នឹង មានបញ្ហាចោរប្លន់គាត់នៅនេះមិនកើតអញ្ចឹងទៅបានគាត់ទៅនៅស្វាយចេក គេឲ្យគាត់នៅបង្រៀននៅស្វាយចេក ។

ដានី ៖ បាទៗ!ប៉ុន្តែដូចថាគាត់ធ្វើគ្រូធ្វើអីហ្នឹងខាងថ្នាក់លើគេរៀបចំដាក់ឲ្យគាត់ម៉ោធ្វើគ្រូឬក៏ម៉េច?

ហឿន ៖ អានេះកាលនោះប្រទង់ប្រទាញ គេគិតថា អ្នកណាមានសមត្ថភាពចេះដឹងគេជ្រើសរើសធ្វើជាគ្រូ យើងចុះឈ្មោះពីក្រោមទៅលើ មិនចឹង ។

ដានី ៖ អូ!

ហឿន ៖ គេរើសមើលថាអ្នកណាចេះដឹងអីអាចធ្វើគ្រូកើតអី គេដាក់ឈ្មោះធ្វើគ្រូទៅ ។

ដានី ៖ បាទៗ!

ហឿន ៖ យើងឡើងឈ្មោះទៅលើទៅ បានខាងលើគេគិតជាលុយខែតិចតួចឲ្យម៉ោ ខំបង្រៀនគេទៅ គាត់ចេះជាងគេនៅនេះ ។

ដានី ៖ បាទៗ! ប្រពន្ធគាត់ឈ្មោះយាយម៉ៅ?

ហឿន ៖ បាទ!យាយម៉ៅ យាយរុំហៅយាយម៉ៅ តែស្រុកនេះហៅយាយម៉ៅៗ ។

ដានី ៖ គាពិន ម៉េច អត្តចរិកគាត់មកនៅក្នុងស្រុកភូមិយើងគាត់ម៉េច?

ហឿន ៖ បាទ!ម៉ោនៅនេះខ្ញុំ ខ្ញុំមើលគាត់ៗមិនដែលទោមនោសស្សអីជាមួយបងប្អូនណា ឲ្យបងប្អូនណាឈឺក្បាលព្រោះរឿងគាត់ទេ គាត់រក្សាសុខដែរណាស់ ។

ដានី ៖ គាត់រក្សាសុខដែរ?

ហឿន ៖ បាទ! ហើយគាត់អ្នកចេះមិនចឹង! ប៉ុន្តែគ្រាន់តែថាមិនជិតខាងអីទៅ ពេលដើរទៅលេង ប៉ះគាត់កំពុងហូបបាយមិនសួរគេស៊ីបាយទេ ច្រើនតែស៊ីរួចបានមកលេងអីអន្ទុយលេង ជាមួយគេទៅណា៎ ។

ដានី ៖ អ្ហូ!

ហឿន ៖ មិនសួរគេស៊ីបាយ មិនសួរអីណាណីទេគាត់ មនុស្សដូចថាមនុស្សប្រកាន់ខ្លួនដែរ ។

ដានី ៖ ប្រកាន់ខ្លួនដែរ?

ហឿន ៖ បាទ! ព្រោះគាត់អ្នកធំពីដើមម៉ោយូរដែរហើយ ។

ដានី ៖ បាទ! ហើយគាត់មកនៅបានប៉ុន្មានឆ្នាំទៅ?

ហឿន ៖ ឆ្នាំបញ្ចូរចោរប្អូនមើល៍ឆ្នាំ៩៤-៩៥នេះឯង ។

ដានី ៖ គាត់ទីមមកនៅបាន២ឆ្នាំទេ ។

ហឿន ៖ ហ្នឹងហើយ៩៥-៩៦ហើយ ៩៧បានយើងធ្វើសម៉ាហរណកម្មថ្ងូកណា៎ បាទ!៩៦-៩៧ហើយ ។

ដានី ៖ បាទ!

ហឿន ៖ ប៉ុនគាត់មកលេងនេះយូរដែរ មើល៍ជិត១០ឆ្នាំហើយ ។

ដានី ៖ បាទ!ចុះពេលហ្នឹងដូចថាខាងលើគេផ្ញើរឲ្យមើលសន្តិសុខអី ដល់ពេលគាត់មានបញ្ហាអី ខាងលើគេមានម៉ោ ម៉េចដែរពូ ដូចថាពេលគាត់មកនៅហ្នឹងយើងមានមើលថែរក្សាសន្តិសុខគាត់បអត់?

ហឿន ៖ បាទ! ពេលនោះខ្ញុំអស់អំណាចវិញ ។

ដានី ៖ ពូអស់អំណាចហើយ?

ហឿន ៖ បាទ!អស់ហើយ ដោយគេត្រូវគ្នា៩៣គេមិនរួមគ្នាវៃខ្មែរក្រហម ។

ដានី ៖ បាទ!

ហឿន ៖ គេរួមគ្នាវៃខ្មែរក្រហមអញ្ចឹងទៅ ខ្ញុំចុះចូលតាមរយៈមិត្តភក្រខ្ញុំប៉ា៉ហ្នឹង ខ្ញុំចុះចូលខ្ញុំ ប្រគល់អាវុធឲ្យគេរាប់រយដើម ។

ដានី ៖ អ្ហូ!

ហឿន ៖ បាទ! ព្រោះខ្ញុំមិនចង់បង្ក បង្ហូរឈាមគ្នាទៀត ។

ដានី ៖ អ្ហូ!អញ្ចឹងអេស៎?

ហឿន ៖ បាទ!

ដានី : ចុះចុះចូលឆ្នាំណា?

ហឿន : បាទ!ខ្ញុំចូល៩៣ហ្នឹង ។

ដានី : ៩៣ពេលបោះឆ្នោតហ្នឹង?

ហឿន : ពេលបោះឆ្នោតហ្នឹង ។

ដានី : បាទ!ពូចុះចូលដែរ?

ហឿន : ៩៣-៩៤ហើយ ។

ដានី : ពេលពូចុះចូលម៉ោមានម៉ោធ្វើការទៀតយ៉ាងម៉េច?

ហឿន : បាទ!ពេលនោះគេអូសទាញខ្ញុំឲ្យចូលធ្វើការវិញ ធ្វើខាងក្នុងហ្នឹងគេឲ្យវរសេនីយ៍សក្តិ៤ដែរ ។

ដានី : សក្តិ៤?

ហឿន : បាទ! អាជេងនេះគេសក្តិ៣ ។

ដានី : បាទ!មកធ្វើការជាមួយកងពល?

ហឿន : កងពល៥១ ពីដើមកងពលទី៧ ។

ដានី : តួនាទីអីគេដល់ពេលយើងបានម៉ោចូល?

ហឿន : បាទ!យើងបាន អ៊ីអាជេងគេបានវរអញ្ចឹងទៅ ខ្ញុំបាន កាលនោះគេឲ្យខ្ញុំរងវរសេនាធំ មានវរសេនាធំ កាលគេមិនទានលដ្ឋាច់វរសេនាធំទេ គេនៅកាន់របៀបកម្មុយនីស មានវរសេនាធំ វរសេនាតូច ។

ដានី : បាទ!

ហឿន : មានកងពលតូច កងពលធំ ។

ដានី : គេឲ្យពូម៉ោរងវរសេនាធំ?

ហឿន : បាទ!រងវរសេនាធំ ។

ដានី : អញ្ចឹងពូផ្តាច់ទំនាក់ទំនង ?

ហឿន : ខ្ញុំដាច់ទំនាក់ទំនងជាមួយគាត់ហើយ ជាមួយតាពិន ជាមួយអីហ្នឹង ។

ដានី : បាទ!ចុះកាលពីគាត់ប្រាប់ពូថាគាត់ឈ្មោះ កាំង ហ្គាអាវ ហើយឈ្មោះឌុចហ្នឹងប្រាប់ពីអន្លាល់?

ហឿន : បាទ!កាលយើង៩០ អ្ហូ!៨០អ៊ី៩៣-៩២ហ្នឹង ។

ដានី : គាត់មកដល់ហ្នឹងហើយ គាត់ប្រាប់?

ហឿន ៖ គាត់មកនៅនេះហើយ (ប្រពន្ធគាត់៖គាត់មកនៅនេះហើយ គាត់ទៅនៅផ្ទះគាត់ដើង ជិតកន្លែងរទេះដែកនោះ ទិញពីគាត់៥ជី ។

ដានី ៖ បាទ!ចុះតាំងគាត់ចោលប្អូនហ្នឹងយ៉ាងម៉េច ចោរប្អូនបាញ់ប្រពន្ធគាត់យ៉ាងម៉េច?

ហឿន ៖ បាទ!ចោរប្អូនហ្នឹងគេគំរាមគំហែងគាត់ គេប្រើចំពោះទង់ ។

ដានី ៖ ចំពោះទង់?

ហឿន ៖ បាទ!ចាក់ដោយចំពោះទង់ម៉ង១សួរចំលើយរកមាស ចាក់ទៅវាជ្រុល ជ្រុលទៅស្លាប់ប្រពន្ធគាត់ទៅ ។

ដានី ៖ អញ្ចឹងគេចាក់ហ្នឹងចាក់ដើម្បីគាត់បេញមាស?

ហឿន ៖ បាទ!គេឲ្យគាត់ដេកផ្កាប់មុខ ហើយគេយកអាពោះទង់ហ្នឹងចាក់ពីខ្នង ពីក្រោយណា៎ ។

ដានី ៖ បាទ!

ហឿន ៖ ដល់ចាក់ទៅប្រហែលពួកអាចោរប្អូនវាស្រវឹងផង ចាក់ជ្រុល ធ្លុះទៅឈាមហូរចូលក្នុងវិញស្លាប់ទៅ ចុកស្លាប់ ស្លាប់ប្រពន្ធ ហើយគាត់ក៏ដូចគ្នាគេចាក់ពីក្រោយដូចគ្នា គាត់ធ្វើជាស្លាប់ដែរ ដល់ម៉ោ១២យប់ខ្ញុំដឹងរឿងខ្ញុំរត់កាត់ពីនេះទៅ ខ្ញុំទៅកន្លែងគាត់ ខ្ញុំស្រណោះគាត់ដែរ(ប្រពន្ធ៖អ្នកស្រុកយើងគេប្រើលឈូរឆរទៅជួយគ្នា) បាទ!គេប្រាប់ ថាចោរប្អូនគាត់ ខ្ញុំរត់ពីនេះទៅ បានខ្ញុំថាក្តាមកាត់ស្រែណាវានៅស្រែហ្នឹង គ្មាននៅឆ្ងាយពីស្រែហ្នឹងទេ ។

ដានី ៖ បាទ!

ហឿន ៖ អញ្ចឹងទៅក្រុមចោរខ្ញុំស្រាវជ្រាវ កាលហ្នឹងខ្ញុំស្រាវជ្រាវបានទាំងអស់ ប៉ុន្តែគាត់នេះដោយគាត់ទៅជឿក្រុមសាសនាហ្នឹងទៅ ហើយប្រវត្តិគាត់ធ្វើបាបគេផងទៅ បានគាត់គិតថាវាយើងសាងបាបសាងកម្មអីជាមួយពួកអស់ហ្នឹង ។

ដានី ៖ បាទ!

ហឿន ៖ គាត់បញ្ចប់តុលាការគេនេះទៅ គេឲ្យគាត់គាត់៥ ០ ០ ០បាត កាត់ទោសពួកទាំងឡាយ ហ្នឹងក្រុមចោរហ្នឹង ។

ដានី ៖ គេចាប់បានដែរចោរហ្នឹង?

ហឿន ៖ ចោរហ្នឹងបើយើងស្គាល់អស់ហើយហ្នឹង យើងស្គាល់កន្លែង ។

ដានី ៖ អ្នកនៅក្នុងហ្នឹងដែរ?

ហឿន ៖ អ្នកនៅនេះខ្លះ មានអ្នកក្រៅខ្លះ ។

ដានី ៖ ហើយចោរហ្នឹងយ៉ាងម៉េច ដល់ពេល មាសគាត់មានមែនប៉ុក៏យ៉ាងម៉េច បានចោរហ្នឹងវាដឹងម៉ោប្លន់មាសគាត់?

ហឿន ៖ មានមាសខ្លះមែនមិនអត់ទេ ។

ដានី ៖ តែគាត់ចោរប្លន់អត់បានទេ បានតែរបស់ជាប់នៅនឹងខ្លួនគាត់?

ហឿន ៖ បានៗតែក្រវិលអីតិចតួចហ្នឹង បើអាមាសដុំគាត់នោះអត់បានទេ ។

ដានី ៖ គាត់ទុកនៅណាទៅមាសដុំ?

ហឿន ៖ គាត់លាក់រួចហើយ ខ្ញុំទៅដល់យប់ម៉ោ១ ម៉ោង១២យប់ គាត់ឲ្យកូនគាត់ហ្នឹងទៅកាយមាសពីជើងសរសរ ជើងសរសរផ្ទះគាត់ហ្នឹង កាយតែខ្ញុំអត់សុំមើលទេ ខ្ញុំអត់សុំ មើល?

ដានី ៖ អ្ហូ!អញ្ចឹងមាសហ្នឹងគាត់អត់បាត់បង់ទេ?

ហឿន ៖ អត់បានបាត់បង់ទេ ។

ដានី ៖ មាសគាត់ច្រើនមែនអញ្ចឹង?

ហឿន ៖ មិនដឹងប៉ុណ្ណា ដ៏មិនបានមើលអញ្ចឹង អាទៅយប់ហើយ ពេលដែលឃើញខ្ញុំទៅ អន្លុយលេងម៉ាសន្ទុះអញ្ចឹងទៅ បានគាត់ហៅកូនគាត់ឲ្យកាយកំណប់នៅឯជើងសរសរគាត់ ហ្នឹង ។

ដានី ៖ គាត់ទុកចិត្តពូ?

ហឿន ៖ បាទ!គាត់ទុកចិត្តខ្ញុំ ។

ដានី ៖ អ្នកភូមិអត់ដឹងទេ?

ហឿន ៖ អ្នកភូមិអត់ដឹងទេ គាត់កាយយប់ តែខ្ញុំក៏អត់បានសុំមើលគាត់ថា មើលសុំមើលមាសហ្នឹងប៉ុណ្ណាអី ស្អីលុយប៉ុណ្ណាអីអត់សុំមើលទេ បានខ្ញុំថាអើឡើងឡានគាត់ហើយ ដឹកគាត់យកទៅ ខ្ញុំឲ្យអាម៉ឺននេះជូនទៅវាពេទ្យផង ។

ដានី ៖ បាទ!អ្ហូ!ដឹកទៅហើយម៉េចទៀតទៅ ក្រោយម៉ោមានទំនាក់ទំនងម៉េចជាមួយគាត់?

ហឿន ៖ បាទ!ខ្ញុំស្រាវជ្រាវខាងមេរបស់ខ្ញុំខ្មែរក្រហម អតីតហ្នឹងទៅនៅរោងស៊ីបរបស់តាអុលៗរោងស៊ីបបន្ទាយមានជ័យហ្នឹង ។

ដានី ៖ បាទ!

ហឿន ៖ អញ្ចឹងខ្ញុំប្តឹងទៅគាត់ហ្នឹងបានគាត់ឲ្យស្រាវជ្រាវរកក្រុមចោរហ្នឹង ។

ដានី ៖ បាទ!

ហឿន ៖ ដល់ស្រាវជ្រាវរកឃើញបែបបទគ្រប់គ្រាន់អស់ហើយ ឈ្មោះអីបានដឹងអស់ហើយ ។

ដានី ៖ បាទ!ចាប់បានដែរ?

ហឿន ៖ ប៉ុន្តែ ចាប់បានខ្លះយកទៅហើយ ប៉ុន្តែគាត់នេះដូចថាអត់ចង់ប្រឈមមុខអីតទៅទៀត សង្រ្គាមធ្វើឲ្យគេមានទុក្ខ មានកម្មអីដោយសារគាត់ណាស់ ។

ដានី ៖ បាទ!

ហឿន ៖ គាត់ចង់បញ្ចប់បាបកម្ម ព្រោះគាត់សាងទៅលើគេច្រើនរួចទៅហើយ យើងអត់ដឹង រឿងអាកាលនោះ ។

ដានី ៖ បាទ!

ហឿន ៖ ដល់អញ្ចឹងគាត់ថាចប់ទៅអាហ្នឹង ស្រេចតែព្រះហើយ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ហើយ ហ្នឹងស្រេចតែព្រះ ។

ដានី ៖ គាត់ចូលយាស៊ូ?

ហឿន ៖ បាទ!គាត់ទៅចូលយាស៊ូហ្នឹង ។

ដានី ៖ ចូលតាំងពីមុនម៉ោនៅហ្នឹងឬយ៉ាំងម៉េច?

ហឿន ៖ ចូលតាំង ពីមុន អ្ហឺ!ម៉ោនៅហ្នឹងចូលគេទៅ ប៉ុនមិនដឹងថាគេលួចចូលពីអន្តរាល់ខ្ញុំមិនដឹង ទេ ។

ដានី ៖ ដល់ក្រោយម៉ោពេលដែលគាត់ទៅនៅស្វាយចេក មានដឹងយ៉ាំងម៉េចទៀតទេ?

ហឿន ៖ អ្ហឺ!នៅស្វាយចេកធ្វើគ្រូធ្វើអីនៅស្វាយចេកហ្នឹង ទៅម៉ោៗតែដល់ពេលនេះ គាត់ដូចអត់ទុកចិត្តនៅហ្នឹង ។

ដានី ៖ បាទ!

ហឿន ៖ អត់មានក្បាល មានកន្ទុយអីច្បាស់លាស់ គាត់ទៅនៅជាមួយប្អូនគាត់នៅសំឡូតទៅ ។

ដានី ៖ បាទ!

ហឿន ៖ ទៅនៅសំឡូតទៅ ទៅនៅនោះទៅធ្វើគ្រូនោះទៀត ចុះឈ្មោះធ្វើអីគេទៀតទៅ ដល់រឿងរ៉ាវហ្នឹងវាបែកការអញ្ចឹងទៅ បានដឹងដល់ទៅអន្តការដឹងអីទៅ ដឹងរិះគន់អញ្ចឹងទៅបែកដល់រាជរដ្ឋាភិបាលអញ្ចឹងទៅ បានគេហៅគាត់យកទៅឃុំខ្លួនទុកហ្នឹង ។

ដានី ៖ អ្ហឺ!បាទ ។

ហឿន ៖ រឿងវាទៅអញ្ចឹងទៅណា៎ ។

ដានី ៖ បាទៗ!

ហឿន ៖ បាទ!បើគាត់ទៅក្រៅផុត វាផុតបាត់ហើយ គេរកណាបានឃើញយើងទៅបាត់ហើយមិនចឹង ។

ដានី ៖ បាទ!ចុះសព្វថ្ងៃហ្នឹងទៅធ្វើទាហាននៅណា នៅភូមិភាគ៥?

ហឿន ៖ បាទ!ខ្ញុំធ្វើភូមិភាគ៥ ។

ដានី ៖ ពូមានតួនាទីអីដែរនៅភូមិភាគ៥?

ហឿន ៖ បាទ!ខ្ញុំនៅកន្លែងក្រុម(ក២)របស់ភូមិភាគ៥ តែខ្ញុំក្រោយម៉ោខ្ញុំមានបញ្ហារឿងគណបក្សតិចតួចណាស់ ។

ដានី ៖ បាទ!

ហឿន ៖ ដោយសារតែមានមិត្តភក្ដិគេចោទប្រកាន់ ខ្ញុំហ្នឹងក៏យកផ្លូវឈ្មោះចោលទៅ ផ្លូវឈ្មោះទុកទៅ ដល់ខែទៅគេឲ្យលុយខ្វះខែណាឲ្យគេបាយខ្វះទៅណា៎ ។

ដានី ៖ បាទ!

ហឿន ៖ ហើយឥឡូវនេះគេថាចាំមើលចែកឆ្នាំនេះប្រធានយើងដល់អាណត្តិហ្នឹង ប្រធានយើងត្រូវកែទំរង់រៀបចំតំឡើងសក្តិអីថែមទៀតណា៎ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!អញ្ចឹងបានគេត្រូវទម្លាក់ឈ្មោះខ្ញុំម៉ោនៅក្នុងស៊ុបនេះ ក្នុងខេត្តបន្ទាយមានជ័យយើងនេះ លោក នន់ ណារ៉ា នេះឯង គាត់នៅជានាយអធិការដ្ឋ ។

ដានី ៖ អ្ហូ!

ហឿន ៖ ខាងមេភូមិភាគលេខ៥ហ្នឹង ។

ដានី ៖ បាទៗ!

ហឿន ៖ ឲ្យមកនៅជាអធិការដ្ឋប៉ុនខ្ញុំសព្វថ្ងៃប្រមូលប្រមូលផ្សេងៗបានលុយខ្វះហ្នឹងទៅជួប តាសេនៗ សារឿន ហៅ សេន ហ្នឹងណា៎ ។

ដានី ៖ បាទ!

ហឿន ៖ ជាមេរបស់ហ៊ុន សែន ដែលនៅសម័យ៣ឆ្នាំនោះណា៎ ។

ដានី ៖ បាទ!

ហឿន ៖ គាត់ជាអ្នកការប្រពន្ធការអីឲ្យ ហ៊ុន សែន ហ្នឹងគឺគាត់ហ្នឹង ។

ដានី ៖ បាទ!ស្គាល់គាត់ដែរ?

ហឿន ៖ ស្គាល់!ខ្ញុំទៅជួបគាត់ហ្នឹង ឲ្យគាត់ជួយសារវេប្តូរកន្លែងនៅ ចេញពីភូមិភាគ៥ទៅភូមិភាគ៤វិញ ទៅនៅជាមួយកងពល៤២ជាមួយ ប៉ែន រ៉ូយ នោះណា៎ ។

ដានី ៖ អ្ហូ!ទៅនៅជាមួយគ្នាយើងចាស់វិញ?

ហឿន ៖ ទៅនៅជាមួយគ្នាចាស់វិញ ។

ដានី ៖ បាទ!យើងធ្លាប់នៅជាមួយគ្នា ដឹងប្រវត្តិគ្នា?

ហឿន ៖ បាទ!ដឹងសុខទុក្ខគ្នា ហើយដឹងថាយើងធ្វើអីកើត ធ្វើអីមិនកើត មិនចឹង ។

ដានី ៖ បាទៗ!

ហឿន ៖ បើនៅជាមួយពួកអាជ្រទល់ខេត្តនេះអត់ដឹងទេ ដឹងតែថាឲ្យតែអាណាមានលុយ ឲ្យអាហ្នឹងធ្វើមេម៉ង់ ។

ដានី ៖ បាទៗ!

ហឿន ៖ នេះមេសព្វថ្ងៃសព្វថ្ងៃគំនិតចេញពីអ្នកមានលុយទេ ។

ដានី ៖ បាទៗ!

ហឿន ៖ អត់មានគិតពីប្រវត្តិតស៊ូច្បាស់លាស់ ធ្វើកើតធ្វើមិនកើតអីទេ នយោបាយមានមិនមានអីទេ ។

ដានី ៖ បាទៗ!

ហឿន ៖ បាទ!ខ្មែរក្រហមពួកខ្មែរក្រហមអតីត ត្បិតតែវានេះមែននៅតែវាគិត មេធ្វើការគេឲ្យ ធ្វើអ្នកធ្វើមិនកើតគេឲ្យនៅក្រោយ ។

ដានី ៖ បាទៗ!

ហឿន ៖ មិនអញ្ចឹង!មិនទាត់អ្នកឯងចោលទេ នៅដូចថារៀបអាទេះមួយ អាណាត្រង់ថាធ្វើអា នេះអាណាវៀចទៅធ្វើអានោះ ដើម្បីឲ្យបានអាទេះ តែសព្វថ្ងៃមិននិយាយថាមើល ឆាយទេ រៀបអាណាមានលុយបុកធ្វើមេរហូត ។

ដានី ៖ បាទ!អញ្ចឹងមែន ។

ហឿន ៖ អញ្ចឹងប្រសិនយើងច្បាំងៗមិនឈ្នះគេទេ ។

ដានី ៖ ហ៊ីអ៊ីពូខស្សាហ៍ទៅលេងស្រុកដែរ ទៅលេងឪពុកម្តាយបងប្អូននៅស្រុក?

ហឿន ៖ បាទ!ទៅដែរ ទៅ២-៣ដងដែរ ។

ដានី ៖ ទៅដែរ?

ហឿន ៖ បាទ!

ដានី ៖ ឪពុកពូគាត់អាយុប៉ុន្មានហើយឥឡូវ?

ហឿន ៖ គាត់អាយុ៦០ជាងហើយ ។

ដានី ៖ អាយុ៦០ជាង?

ហឿន ៖ បាទ!៦៧-៦៨ហើយ ។

ដានី ៖ គាត់នៅមាំដែរ?

ហឿន ៖ បាទ!នៅខែងវែងដែរ គាត់អ្នកកីឡាពីដើម (ប្រពន្ធៈខ្វាលគោតែសព្វថ្ងៃ) ។

ដានី ៖ ចុះឥឡូវគាត់ទៅខ្វាលគោ គាត់នៅជាមួយកូន?

ហឿន ៖ នៅជាមួយកូន នៅនោះគាត់មានប្រពន្ធចុងមួយទៀត ។

ដានី ៖ អ្ហ៎!គាត់យកប្រពន្ធចុះមួយទៀត ។ គាត់មានដែរមកលេងនេះឬអត់?

ហឿន ៖ ម៉ោគាស៎ ។

ដានី ៖ ចុះកាលជំនាន់ហ្នឹងគាត់ធ្វើសង្កាត់អីអញ្ចឹង ដល់ពេលហ្នឹងគេមានផ្លាស់ប្តូរគាត់រួចខ្លួនដែរ ព្រោះកាលហ្នឹងមាននិរតី ខាងនិរតីគេចាប់គេអី?

ហឿន ៖ បាទ!អត់មានអីដែរ ព្រោះគាត់ធ្លាប់មានប្រវត្តិតស៊ូជាមួយគេដែរ ។

ដានី ៖ អ្ហ៎!គាត់ធ្វើសង្កាត់ហ្នឹងរហូតទៅដល់៧៩ទៅ?

ហឿន ៖ បាទ!ធ្វើរហូតទើបគាត់ឈប់យើងក្រោយនេះ ។

ដានី ៖ គាត់ឈប់ ពេលណា?

ហឿន ៖ គាត់ចូលម៉ោអារដ្ឋកម្ពុជាធ្វើទៀត ។

ដានី ៖ គាត់ធ្វើសង្កាត់ទៀត?

ហឿន ៖ ធ្វើទៀត ធ្វើមេភូមិ គេឲ្យធ្វើមេភូមិ ព្រោះគាត់ប្រជាជនគេស្រឡាញ់គាត់ ។

ដានី ៖ ប្រជាជនស្រឡាញ់គាត់ ធ្វើល្អអញ្ចឹង?

ហឿន ៖ បាទ!ស្រឡាញ់គាត់ធ្វើល្អ គាត់មិនដែលមានទុក្ខមានទោសដោយសារតែគាត់ គាត់ដឹងតែជួយគេ ។

ដានី ៖ អ្ហ៎!

ហឿន ៖ ហើយគាត់អ្នកចេះដែរ គាត់អ្នកបានបួសបានអីដែរ ។

ដានី ៖ បាទ!

ហឿន ៖ អញ្ចឹងចេះតែសុខហើយណាស៎ ។

ដានី ៖ បាទ!គាត់នៅភូមិធម្មានាជ ហ្នឹងដដែល?

ហឿន ៖ បាទ!

ដានី ៖ ប្រពន្ធក្រោយគាត់ឈ្មោះអីទៅ ម្តាយ?

ហឿន ៖ ឈ្មោះ អាត ។

ដានី ៖ ឈ្មោះ អាត?

ហឿន ៖ បាទ!

ដានី ៖ បាទ!អ៊ីសំនួរចុងក្រោយ ពូមានដែលឮតុលាការដែលគេកាត់ទោសរាល់ថ្ងៃនេះ ដូចថា ឌុច កាំងហ្កាអាវ ហង់ ពិន ហ្នឹង មានដែលធ្លាប់បានមើល?

ហឿន ៖ បាទ!ខ្ញុំបានដឹងដែរ តាមទូរទស្សន៍តាមអីហ្នឹងតាមពត៌មានហ្នឹង ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ខ្ញុំបានតាមដានទៅដឹងថាគាត់គេកាត់ទោសត្រូវជាប់គុក ។

ដានី ៖ ដឹងរឿងគាត់ជាមេគុកទួលស្លែងអញ្ចឹងដែរ?

ហឿន ៖ បាទ!ដឹងរឿង ។

ដានី ៖ ពូយល់ឃើញម៉េចដែរ ដូចថាកាលពីមុនគាត់ស្គាល់គាត់តាម ដូចថាយើងមិនបានដឹង ដល់ក្រោយម៉ោបានដឹងថាគេចាប់អញ្ចឹង ដូចថាមានអារម្មណ៍យល់ឃើញយ៉ាងម៉េច វិញ?

ហឿន ៖ បាទ!ខ្ញុំគិតថាគាត់សាកសំនឹងត្រូវមានទោសមែន ព្រោះគាត់មានប្រវត្តិធ្វើបាបមនុស្ស ឃាតអញ្ចឹង ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ហើយអញ្ចឹងទៅ គាត់ធ្វើជាកូនគេដែរ គេបញ្ជាគាត់ដែរ អាហ្នឹងគឺជារឿងរបស់ គាត់ បាទ!អាហ្នឹងគាត់មិនដឹងថាត្រូវជួយគាត់យ៉ាងម៉េច ប៉ុន្តែយើង ដែលខ្ញុំគិតថាឲ្យវា សាកសំទាំងអស់គ្នា អ្នកដែលធ្វើសង្គ្រាមជិនាន់នោះទាំងអស់គ្នាណាស់ ។

ដានី ៖ បាទ!

ហឿន ៖ បាទ!ខ្ញុំចង់ថាគិតបើចិត្តខ្ញុំវិញទេ ចង់ឲ្យគេធ្វើជាតុលាការអន្តរជាតិវិញ ។

ដានី ៖ ឲ្យជាតុលាការអន្តរជាតិវិញ?

ហឿន ៖ បាទ!ជាអន្តរជាតិវិញ កាត់ទោសជាសកល ។

ដានី ៖ កាត់ជាសកល?

ហឿន ៖ បាទ!ចង់ឲ្យកាត់ទៅជាសកលដូចគ្នា អ្នកណាមានទោសចំណែកនៅក្នុងរឿងកម្ពុជាហ្នឹងឲ្យ មានទោសទាំងអស់គ្នា ។

ដានី ៖ បាទៗ!

ហឿន ៖ ដូចអាមេរិចកាំងដែលយក b52 មកទម្លាក់នៅស្រុកខ្មែរអី អាហ្នឹងមួយចំណែកមាន ទោសដូចគ្នា ។

ដានី ៖ បាទៗ!

ហឿន ៖ គួរឲ្យមានទោសរឿងអីទៅទម្លាក់ស្រុកខ្មែរ ខ្មែរបានទោឃ្លានពានអាមេរិចឯណា ។

ដានី ៖ អ្ហ៎!ពូ?

ហឿន ៖ បាទ!ខ្ញុំចង់ឲ្យទៅអញ្ចឹង ក៏ប៉ុន្តែយើងគិតថា មិនចង់ឲ្យអ្នកទាំងឡាយហ្នឹងមកជាប់គុកទេ ឲ្យសងកម្ពុជាវិញ ។

ដានី ៖ មានន័យថា ចង់តុលាការអន្តរជាតិកាត់ទោសទាំងអ្នកផ្សេង ទាំងអ្នកដែលមកពាក់ព័ន្ធនឹងរឿងខ្មែរយើងកាត់ទោសទាំងអស់?

ហឿន ៖ កាត់ទាំងអស់ ជាសកលដើម្បីជាពិភពលោក អាហ្នឹងបានយុត្តិធម៌ ។

ដានី ៖ បាទៗ!

ហឿន ៖ មែនទេបង?

ដានី ៖ បាទៗ!

ហឿន ៖ បើកាត់ទោសតែអ្នកចាញ់ ដូចមិនត្រូវ ដូចអត់ទាន់ត្រូវ ។

ដានី ៖ បាទ!

ហឿន ៖ កាត់ទោសទាំងអស់គ្នា បានវាចំតួម៉ង់ អាណាត្រូវសងកម្ពុជា អាត្រូវអីម៉េចៗ រឿងពាក់ព័ន្ធក្នុងរឿងកម្ពុជាមានរឿងច្រើនណាស់ មិនរឿងតិចទេ កាត់តែធ្វើបាបអ្នកចាញ់ដូចអត់ត្រូវ ។

ដានី ៖ បាទ!

ហឿន ៖ អត់ទាន់ត្រូវជាមានតម្លាភាព មែនទេ?

ដានី ៖ បាទៗ!

ហឿន ៖ អានេះជាបេះដូងរបស់ខ្ញុំគិតឃើញ ។

ដានី ៖ បាទ!

ហឿន ៖ អ្នកណាៗមានទោស គឺត្រូវនៅហ្នឹងទាំងអស់កាត់ទោស មានចំណែកហ្នឹង ចែកគ្នាទៅតាមទោសអ្នកឯងទទ្រក្រិដ្ឋប៉ុនណ្ណា មិនចឹង?

ដានី ៖ បាទៗ!

ហឿន ៖ ហើយរឿងបរទេស លូកដៃរឿងកម្ពុជា ឯងមានចំណេកមានទោស ប៉ុន្តែមិនទាមទារឲ្យអ្នកឯងជាប់គុកទេ អ្នកឯងសងកម្ពុជាម៉ោ អ្នកឯងមានខ្វង់ចង់សង មែនទេ ។

ដានី ៖ បាទ!

ហឿន ៖ ហ្នឹងបានយកលុយហ្នឹង មកអភិវឌ្ឍន៍ប្រទេសបានទៅរួចៗ

ដានី ៖ បាទ!

ហឿន ៖ បើកាត់ទោសតែអ្នកចាញ់ អាមេរិច២-៣នាក់ហ្នឹងមានប្រយោជន៍អីៗ

ដានី ៖ បាទៗ!

ហឿន ៖ គង់តែស្លាប់អាដែល គាត់ចាស់ហើយ មានអី តាៗក្រោយទៀតមិនស្រួលអត់បាន កាត់ទៀតៗ

ដានី ៖ បាទ!

ហឿន ៖ ទុកពន្យាចុះពន្យារឡើងៗស្លាប់បាត់ មានបានធ្វើស្អីៗ

ដានី ៖ បាទៗ! ខ្ញុំអរគុណច្រើនពូ!

ហឿន ៖ បាទ!

«ចប់»